Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

# សៀវភៅ មគ្គុទេសក៍

## គម្រោងឈេន សម្រាប់ការអភិវឌ្ឍន៍ ប្រព័ន្ធទីផ្សារកសិកម្ម



## សម្របសម្រួល ការផ្សារភ្ជាប់អាជីវកម្ម ទៅអាជីវកម្ម (B2B)

របៀបកសាងទំនាក់ទំនងប្រកបដោយផលិតភាព ជាលក្ខណៈសេដ្ឋកិច្ចរវាងកសិករ អ្នកទិញ អ្នកលក់ធាតុចូលកសិកម្ម និងតួអង្គដទៃទៀត នៅក្នុងទីផ្សារកសិកម្ម។

CHAIN

SNV

swisscontact

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

**Swiss Agency for Development and Cooperation SDC**

# សៀវភៅ មគ្គុទេសក៍

## គម្រោងឈេន សម្រាប់ការអភិវឌ្ឍន៍ ប្រព័ន្ធទីផ្សារកសិកម្ម

SNV

swisscontact

## គម្រោងឈេន

### សៀវភៅមគ្គុទេសក៍ សម្រាប់ការអភិវឌ្ឍប្រព័ន្ធទីផ្សារកសិកម្ម

# សម្របសម្រួលការផ្សារភ្ជាប់អាជីវកម្មទៅអាជីវកម្ម (B2B)


ចងក្រងដោយ៖
លោកស្រីបណ្ឌិត ឃឹម គឹមបួយ លោក ខេវិន រ៉ូប៊ិន លោក រិត អូរើម៉ាស៍
លោក លឹម សុគន្ធដារុណ និងកញ្ញា ណេហា ស្រេស្ត្រា



**សូមថ្លែងអំណរគុណចំពោះអ្នកពិនិត្យ និងកែសម្រួល៖**

លោកជំទាវបណ្ឌិត យើ អាស៊ីគិន  អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
លោកស្រី ម៉ារិគិ វ៉ាន់ស្ស៊ី ប្រធានគម្រោង អេសអិនវី យូហ្កាន់ដា
លោក រិគ វ៉ាន់ គូលេន ទីប្រឹក្សាបច្ចេកទេស អេសអិនវីសាកល
លោក ហែម សុវណ្ណារិទ្ធ ប្រធានកម្មវិធី ទីភ្នាក់ងារស្វីសសម្រាប់អភិវឌ្ឍន៍ និងកិច្ចសហប្រតិបត្តិការ
បណ្ឌិត សុខ គឹមឈិន ព្រឹទ្ធបុរសនៃមហាវិទ្យាល័យសេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
លោក ឱ ធី ប្រធានប្រចាំប្រទេស នៃវិទ្យាស្ថានអន្តរជាតិស្តារជនបទឡើងវិញ
លោក អ៊ុក វណ្ណារ៉ា នាយកប្រតិបត្តិរងនៃវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

**និងសូមថ្លែងអំណរគុណចំពោះអ្នកចូលរួមចំណែក៖**

លោក លីម ណាលុច ទីប្រឹក្សាដំណោះស្រាយទឹកឆ្លាតវៃ អេសអិនវី កម្ពុជា
លោក សៀង វណ្ណស៊ីថា ទីប្រឹក្សាបច្ចេកទេស
លោកស្រី យស មន្នីរ័ត្ន អ្នកសម្របសម្រួលទីផ្សារប្រចាំខេត្តក្រចេះ
លោក អុន រើន អ្នកសម្របសម្រួលទីផ្សារប្រចាំខេត្តស្ទឹងត្រែង
លោក ស្រី សុខជា អ្នកសម្របសម្រួលទីផ្សារប្រចាំឧត្តរមានជ័យ
លោក សោម សាល អ្នកសម្របសម្រួលទីផ្សារប្រចាំខេត្តព្រះវិហារ
មន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អ្នកសម្របសម្រួលទីផ្សារប្រចាំខេត្ត

**រចនា និងរៀបចំបោះពុម្ពផ្សាយ៖** ក្រុមហ៊ុន អិ.ម អ. អេ ឌីហ្សាញ
**រៀបចំរូបភាព៖** គម្រោងឈេន
**អ្នកនិពន្ធ៖** រ៉ូណាល់ដូ ម៉ុងតេកាល់វ៉ូ
**បកប្រែជាភាសាខ្មែរ៖** លោក ង៉ែត សុភា



**គម្រោងសាកវប្បកម្មកម្ពុជាដើម្បីបង្កើនប្រាក់ចំណូលនិងអាហារូបត្ថម្ភ (ឈេន) អេសអិនវី កម្ពុជា និងអគ្គនាយកដ្ឋានកសិកម្ម**

អ៊ីមែល៖ horticulturecambodia@gmail.com
វិបសាយ៖ https://web.maff.gov.kh
ហ្វេសប៊ុក៖ @សាកវប្បកម្មកម្ពុជា Horticulture in Cambodia

## ការណែនាំផ្សេងទៀតនៅក្នុងសៀវភៅ

- ការណែនាំការអភិវឌ្ឍប្រព័ន្ធទីផ្សារ (MSD101)
- ការបង្កើតក្រុមកសិករប្រកបដោយប្រសិទ្ធភាព
- ការសម្របសម្រួលការអភិវឌ្ឍបណ្តុំអាជីវកម្ម
- គំរូបែងចែក និងចំណាត់ថ្នាក់កសិករ
- ការសម្របសម្រួលទំនាក់ទំនងផ្សារភ្ជាប់អាជីវកម្មទៅអាជីវកម្ម
- វិធីសាស្ត្រពង្រឹងសមត្ថភាពកសិករគំរូ
- វិធីសាស្ត្រពន្លឿនអាជីវកម្មជនបទ
- បច្ចេកទេសគ្រប់គ្រងទឹក និងបន្សាំអាកាសធាតុឆ្លាតវៃ សម្រាប់គម្រោងសាកវប្បកម្ម

# តារាងមាតិកា


១. សេចក្តីផ្តើម ១

២. ប្រវត្តិ ២

៣. ទិដ្ឋភាពទូទៅនៃវិធីសាស្រ្ត ៣

៤. ជំហាននៃអាជីវកម្មទៅអាជីវកម្ម ៦

៥. សេចក្តីណែនាំជាជំហានៗ ៧

៥.១ ប្រមូលព័ត៌មានទីផ្សារ ៧

៥.២ វិភាគព័ត៌មានទីផ្សារ ៩

៥.៣ រៀបចំកិច្ចប្រជុំក្រុមកសិករ ១១

៥.៤ ផ្គូផ្គងក្រុមកសិករជាមួយទីផ្សារ ១៣

៥.៥ អនុវត្តន៍កិច្ចប្រជុំក្រុមកសិករ ១៥

៥.៦ សម្របសម្រួលផែនការផលិតកម្ម ១៨

៥.៧ សម្របសម្រួលកិច្ចព្រមព្រៀង ២០

៥.៨ តាមដាន ២២

៦. សន្និដ្ឋាន ២៤

ឧបសម្ព័ន្ធ ២៥

# ១. សេចក្តីផ្តើម

គម្រោងសាកវប្បកម្មកម្ពុជាដើម្បីបង្កើនប្រាក់ចំណូលនិងអាហារូបត្ថម្ភ ហៅកាត់ថា (គម្រោងឈេន) បានផលិតចេញនូវសៀវភៅមគ្គុទេសក៍ (How-to Guides) ជាភាគៗបន្តបន្ទាប់ មានចំណងជើងខុសៗគ្នា ដែលមានខ្លឹមសារជាឯកសារណែនាំព័ត៌មានអំពីការអនុវត្តជាក់ស្តែង សម្រាប់ភាគីពាក់ព័ន្ធដែលមានបំណងចង់ចម្លងតាម និងក៏ចង់ធ្វើការកែលម្អ បន្ថែមដើម្បីអោយកាន់តែមានភាពប្រសើរឡើង ទៅលើវិធីសាស្ត្រទាំងឡាយដែលគម្រោងឈេនបានប្រើប្រាស់ក្នុងអំឡុងពេលបីវគ្គនៃគម្រោង។ យើងសង្ឃឹមថាសៀវភៅមគ្គុទេសក៍គ្រប់ភាគទាំងអស់នេះ នឹងមានសារៈប្រយោជន៍ទៅដល់ស្ថាប័នផ្សេងៗទូទាំងពិភពលោក ជាពិសេសអ្នកដែលធ្វើការងារពាក់ព័ន្ធលើគម្រោងអភិវឌ្ឍន៍វិស័យកសិកម្ម ព្រមទាំងអនុវត្តន៍វិធីសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធទីផ្សារ (មើលប្រអប់០១)។ ចំពោះសៀវភៅមគ្គុទេសក៍ទាំងនេះ គម្រោងឈេនបានសហការចងក្រង ជាមួយភាគីពាក់ព័ន្ធនានានៅក្នុងប្រទេសកម្ពុជា ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកសិកម្ម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀត។



សៀវភៅមគ្គុទេសក៍មួយនេះផ្តោតលើវិធីសាស្ត្រផ្សារភ្ជាប់អាជីវកម្មទៅអាជីវកម្មរបស់គម្រោងឈេន។ យើងបានធ្វើការសម្របសម្រួលកសិករដាំបន្លែទាំងស្ត្រីទាំងបុរស ដែលត្រូវការពង្រឹងសមត្ថភាពអាជីវកម្មរបស់ពួកគេ និងត្រូវការ-ការកសាងទំនាក់ទំនងប្រកបដោយផលិតភាពសេដ្ឋកិច្ច ជាមួយតួអង្គទីផ្សារអាជីវកម្មនានា រួមមាន៖ អាជីវករទិញបន្លែ អ្នកលក់ធាតុចូលកសិកម្ម និងអ្នកផ្តល់សេវាកម្មបច្ចេកទេស។ ទោះបីការផ្តោតចំបងគឺកសិករគម្រោងឈេនក៏បានប្រឹងប្រែងធ្វើការផងដែរដើម្បីធានាថា ទំនាក់ទំនងផ្សារភ្ជាប់អាជីវកម្មទៅអាជីវកម្ម គឺជាយុទ្ធសាស្ត្រ ឈ្នះ ឈ្នះ ដោយគ្រប់ភាគីពាក់ព័ន្ធអាចទទួលបាននូវចំណូលខ្ពស់ ដែលនេះជាកត្តាលើកទឹកចិត្តមួយដើម្បីទ្រទ្រង់ទំនាក់ទំនងអាជីវកម្មទាំងនេះបន្ទាប់ពីគម្រោងឈេនត្រូវបានបញ្ចប់។

សៀវភៅមគ្គុទេសក៍នេះត្រូវបានចាត់ទុកជាឯកសារវឌ្ឍនភាពមួយ ដែលទាមទារការបន្តកែសម្រួលដើម្បីអោយមានភាពប្រសើរឡើងពីដំណាក់កាលមួយទៅដំណាក់កាលមួយ។ អ្នកដែលមានបំណងប្រើប្រាស់វិធីសាស្ត្រដូចព៌ណនាខាងក្រោមនេះ គួរមានការកែសម្រួលវិធីសាស្ត្រអោយសមស្របទៅនឹងបរិបទ និងតម្រូវការជាក់លាក់ផ្អែកទៅលើកត្តាផ្សេងៗជាច្រើនដូចជា៖ ភូមិសាស្ត្រ ពេលវេលាកំណត់ ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ចំណាប់អារម្មណ៍ និងពេលវេលាសមរម្យរបស់ដៃគូ បុគ្គលិកលក្ខណៈជាក់លាក់នៃទីផ្សារ និងវិស័យនានា។

### ប្រអប់០១ ៖
### ការអភិវឌ្ឍប្រព័ន្ធទីផ្សារ (MSD)

វិធីសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធទីផ្សារគឺគ្របដណ្តប់ប្រព័ន្ធទាំងមូលជុំវិញទីផ្សារ។ ក្នុងករណីសាកវប្បកម្មនេះ ទិដ្ឋភាពរួមនៃទីផ្សារគឺរួមបញ្ចូលអ្នកចូលរួមពាក់ព័ន្ធទាំងអស់ (តួអង្គ ឬអ្នកដើរតួនាទី)៖ កសិករដែលដាំដុះដំណាំ អ្នកផ្គត់ផ្គង់គ្រាប់ពូជ និងអ្នកលក់ធាតុចូលកសិកម្មផ្សេងៗទៅអោយកសិករ អាជីវករដែលទិញផលដំណាំនៅពេលប្រមូលផល និងអ្នកលក់នៅផ្សារនានាទៅអោយអ្នកប្រើប្រាស់ចុងក្រោយ។ សេវាកម្មនានាដែលគាំទ្រជាស្នូលដល់ការងារទីផ្សារ ក៏រួមបញ្ចូលផងដែរ ក្នុងនោះមានដូចជា៖ ភ្នាក់ងារផ្សព្វផ្សាយរដ្ឋាភិបាលដែលផ្តល់ដំបូន្មានទៅកសិករ និងរចនាសម្ព័ន្ធទីផ្សារក្នុងតំបន់ ដែលរៀបចំទីធ្លាសមរម្យល្អសម្រាប់អ្នកលក់ និងអ្នកទិញជួបគ្នា។

ការអភិវឌ្ឍប្រព័ន្ធទីផ្សារមានគោលបំណងដោះស្រាយបញ្ហាភាពក្រីក្រ តាមរយៈការធ្វើអោយប្រសើរឡើងនូវការអនុវត្តទីផ្សារនៅក្នុងបែបផែនបរិយាបន្ន ជាពិសេសការសម្របសម្រួលលើកទឹកចិត្តផ្លាស់ប្តូរឥរិយាបទអាជីវកម្ម និងតួអង្គទីផ្សារដទៃទៀត ដើម្បីធានានូវការផ្លាស់ប្តូរទ្រង់ទ្រាយធំដែលទទួលបានអត្ថប្រយោជន៍យូរអង្វែង។



# ២. ប្រវត្តិ

សាកវប្បកម្មដើរតួនាទីជាផ្នែកមួយសំខាន់សម្រាប់សេដ្ឋកិច្ចកសិកម្មនៃប្រទេសកម្ពុជា ដោយសារទំហំនៃការប្រើប្រាស់បន្លែ ផ្លែឈើនៅក្នុងតំបន់ទីក្រុងមានការកើនឡើងយ៉ាងឆាប់រហ័ស។ រហូតមកដល់បច្ចុប្បន្ននេះ ជាង ៥០% នៃបន្លែសរុប ត្រូវបាននាំចូលពីប្រទេសជិតខាងដែលមានសមត្ថភាពផលិតបានពេញមួយឆ្នាំ បំពាក់ដោយបណ្ដាញបច្ចេកទេសកាន់តែប្រសើរ និងលក់ផលិតផលបានក្នុងតម្លៃប្រកួតប្រជែងជាងបន្លែក្នុងស្រុក។ ទោះបីយ៉ាងណាក៏ដោយ ភាគច្រើននៃបន្លែនាំចូលនៅមានផ្ទុកបរិមាណកាកសំណល់ថ្នាំសម្លាប់សត្វល្អិតច្រើនគួរអោយកត់សម្គាល់ ដែលបង្ករការព្រួយបារម្ភលើសុវត្ថិភាពចំណីអាហារ។ នៅក្នុងវគ្គ១ និងវគ្គ២ (២០១៤-២០២០) គម្រោងឈេនបានធ្វើការលើកស្ទួយការផលិត និងប្រើប្រាស់បន្លែសុវត្ថិភាពក្នុងស្រុក នៅក្នុងបណ្តាខេត្តភាគខាងជើងទាំងបួននៃប្រទេសកម្ពុជា (ឧត្តរមានជ័យ ព្រះវិហារ ស្ទឹងត្រែង និងក្រចេះ)។



មកដល់បច្ចុប្បន្ន គម្រោងឈេនសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ការផ្គត់ផ្គង់បន្លែក្នុងស្រុកនៅក្នុងបណ្ដារខេត្តគោលដៅទាំងបួនកើនឡើងពី៥០% ទៅ៦៥%
- ការគាំទ្ររបស់គម្រោងបានឈានដល់ ១០,០០០ គ្រួសារនៃក្រុមកសិករចំនួន៤០០ក្រុម។ (ច្រើនជាង៧០% ជាកសិករស្ត្រីដែលទទួលបានការគាំទ្រ។)
- កសិករប្រហែល៦,០០០នាក់ បានផ្លាស់ប្តូរពីការដាំដុះដើម្បីជីវភាពគ្រួសារ មកប្រតិបត្តិការជាកសិករដាំដុះពាក់កណ្ដាលអាជីព ឬអាជីព។
- អាជីវករចំនួន៦៥នាក់ទូទាំងបណ្ដាខេត្តគោលដៅបានបង្កើនប្រភពប្រមូលបន្លែក្នុងស្រុក។
- អ្នកលក់ធាតុចូលកសិកម្មចំនួន២៥នាក់ (ភាគច្រើនជាស្ត្រី) ទូទាំងបណ្ដាខេត្តគោលដៅបានបង្កើនការលក់របស់ខ្លួន។
- បណ្ដុំអាជីវកម្មចំនួន១៤ ត្រូវបានបង្កើតឡើង និងពង្រឹង។



# ៣. ទិដ្ឋភាពទូទៅនៃវិធីសាស្ត្រ

## អ្វីទៅជាបញ្ហា ?

គម្រោងឈេនបានរកឃើញថា កសិករជាច្រើននៅក្នុងបណ្តាខេត្តក្រីក្រនៃប្រទេសកម្ពុជា បានប្រឈមនឹងបញ្ហាមួយចំនួន៖ ជារឿយៗ ពួកគេមិនអាចលក់ផលិតផលរបស់ខ្លួនអស់ ពីព្រោះពួកគេខ្វះទំនាក់ទំនងទៅកាន់អ្នកទិញ ជួនកាលពួកគេបង្កើនផលិតកម្មលើមុខដំណាំជាក់លាក់ ប៉ុន្តែប្រឈមនឹងតម្រូវការទីផ្សារ និង/ឬតម្លៃទាបទៅវិញ ព្រមទាំងកង្វះខាតតួអង្គទីផ្សារដែលមានចំណាប់អារម្មណ៍ និងសកម្មក្នុងការផ្គត់ផ្គង់ធាតុចូលសាកវប្បកម្ម។ ក្រុមការងារគម្រោងឈេនបានចាប់ផ្តើមគិតអំពីវិធីជំរុញការផ្សារភ្ជាប់រវាងតួអង្គទីផ្សារ និងវិធីកៀរគរចំណាប់អារម្មណ៍ ព្រមទាំងសកម្មភាពលើវិស័យសាកវប្បកម្មនៅកម្រិតថ្នាក់ខេត្ត។

## អ្វីទៅដែលរំពឹងថានឹងសម្រេចបាន ?

គម្រោងឈេនបានរៀបចំដំណោះស្រាយដែលយើងជឿជាក់គឺ៖ (១) កសាងទំនាក់ទំនងអោយកាន់តែប្រសើរឡើងរវាងកសិករ និងតួអង្គទីផ្សារនានាដូចជា អ្នកប្រមូលទិញបន្លែ អ្នកលក់ធាតុចូលកសិកម្ម និងអ្នកផ្តល់សេវាកម្មបច្ចេកទេសវិស័យឯកជន និងសាធារណៈ (២) បង្កើនកិច្ចសហប្រតិបត្តិការរវាងក្រុមកសិករ និងតួអង្គទីផ្សារទាំងនេះ និង (៣) ពង្រឹងទំនុកចិត្តរវាងតួអង្គពាក់ព័ន្ធ។ ដោយផ្តោតលើទំនាក់ទំនងអាជីវកម្ម គម្រោងឈេនសង្ឃឹមថានឹងបានលើកទឹកចិត្តកសិករអោយរៀនគិតអំពីការផ្លាស់ប្តូរខ្លួនពួកគេទៅជាអ្នកធ្វើអាជីវកម្មពិតប្រាកដ។ ជាមួយគំនិតផ្លាស់ប្តូរនេះ យើងក៏បានកំណត់ឈ្មោះថាជា វិធីសាស្ត្រផ្សារភ្ជាប់អាជិវកម្មទៅអាជីវកម្ម (B2B) ហើយសមាជិកនៃក្រុមការងារ និងតំណាងដៃគូរបស់ពួកយើងដូចជា មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរកិច្ចការនារី និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ត្រូវបានទទួលស្គាល់ថាជាអ្នកសម្របសម្រួលការផ្សារភ្ជាប់អាជិវកម្មទៅអាជីវកម្ម។

## អ្វីទៅជាដំណោះស្រាយ/យុទ្ធសាស្ត្រ ?

ដើម្បីសម្រេចបាននូវគោលដៅរបស់គម្រោង ដោយប្រើប្រាស់វិធីសាស្ត្រផ្សារភ្ជាប់អាជិវកម្មទៅអាជីវកម្ម គម្រោងឈេនបានអភិវឌ្ឍវិធីសាស្ត្រប្រាំពីរជំហានដែលពាក់ព័ន្ធការប្រមូល និងវិភាគព័ត៌មានទីផ្សារ ការរៀបចំកិច្ចប្រជុំធ្វើផែនការដាំដុះជាមួយក្រុមកសិករ ផ្គូផ្គងកសិករជាមួយទីផ្សារមូលដ្ឋាន តូបបន្លែលក់រាយ និងចែកចាយនានា ព្រមទាំងជួយពួកគេរៀបចំជំនួបចរចាអាជីវកម្មជាមួយតួអង្គទីផ្សារផ្សេងៗ។ ជំហានទាំងនេះត្រូវបានពណ៌នាលម្អិតនៅក្នុងផ្នែកទី៤។



# លទ្ធផល

**វិធីសាស្ត្រផ្សារភ្ជាប់អាជីវកម្មទៅអាជីវកម្ម ត្រូវបានដាក់បញ្ចូលជាមួយអន្តរាគមន៍ផ្សេងៗរបស់គម្រោងឈេន ដែលបានផលិតជាលទ្ធផលដ៏រឹងមាំ នៅក្នុងបណ្ដាខេត្តគោលដៅ៖**

- កសិករអាជីពចំនួន៣.៤០០នាក់ (៥០% ជាស្ត្រី) បានមើលឃើញផលិតកម្មរបស់ខ្លួនកើនដល់ ៥០%។ ចំណូលប្រចាំឆ្នាំកើនដល់ ៦០០ដុល្លារអាមេរិច ជាមធ្យម។
- អាជីវករទិញបន្លែចំនួន២០នាក់ និងអ្នកលក់ធាតុចូលកសិកម្មចំនួន ២៥នាក់ បានធ្វើការជាមួយកសិករដែលគាំទ្រដោយគម្រោងឈេន និងបានពង្រីកអាជីវកម្មរបស់ពួកគេ។
- ក្រុមហ៊ុនវិស័យឯកជនកម្រិតថ្នាក់ជាតិចំនួន៦ បានធ្វើការទាំងផ្លូវការ និងមិនផ្លូវការជាមួយកសិករដែលគាំទ្រដោយគម្រោងឈេន និងបានពង្រីកកិច្ចប្រឹងប្រែងអាជីវកម្មរបស់ពួកគេនៅក្នុងបណ្ដាខេត្តគោលដៅ។ ក្រុមហ៊ុនមួយចំនួនបានបង្កើនការលក់១០ដងនៅក្នុងបណ្ដាខេត្តគោលដៅទាំងនោះ។
- បុគ្គលិក៤១នាក់មកពីស្ថាបនថ្នាក់ក្រោមជាតិ (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរកិច្ចការនារី និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក) ទទួលបានការបណ្ដុះបណ្ដាលបច្ចេកទេស និងអាជីវកម្ម។ ចំណេះដឹងនៃការងារផ្សារភ្ជាប់អាជិវកម្មទៅអាជីវកម្មនៅមានកម្រិត (៣ក្នុងចំណោម១០នាក់តាមរយៈការវាយតម្លៃចំណេះដឹងដោយគម្រោងឈេន) មុនពេលភ្ជាប់ពួកគេចូលក្នុងគម្រោង ប៉ុន្តែបន្ទាប់ពីចូលរួម និងទទួលបានការបណ្ដុះបណ្ដាលតាមរយៈគម្រោងឈេន ចំណេះដឹងរបស់ពួកគេបានកើនឡើងទ្វេរមួយជាពីរ (៦ក្នុងចំណោម១០នាក់)។
- ១/៤ នៃអ្នកលក់ធាតុចូលកសិកម្មដែលបានចូលរួមក្នុងសកម្មភាពគម្រោងឈេន បានបង្ហាញកំណើននៃការលក់គួរអោយកត់សម្គាល់ ពីព្រោះបច្ចុប្បន្នពួកគេអាចផ្ដល់ដំបូន្មានបច្ចេកទេសផលិត និងទីផ្សារទៅកាន់កសិករដែលបានទិញធាតុចូលកសិកម្មរបស់ពួកគេ។
- ដៃគូនៅមូលដ្ឋានមួយចំនួនបានលើកឡើងថា ផ្នត់គំនិតរបស់ពួកគេបានផ្លាស់ប្ដូរតាមរយៈវត្តមានរបស់គម្រោងឈេន ហើយពួកគេបានយល់ដឹងអំពីសារៈសំខាន់ ក្នុងការលើកទឹកចិត្តកសិករអោយចេះគិតថាខ្លួនជាអ្នកធ្វើអាជីវកម្ម និងការបង្កើតទំនាក់ទំនងជាមួយរាល់តួអង្គទីផ្សារទាំងឡាយ។
- អ្នកមកចុះទស្សនកិច្ច និងអ្នកវាយតម្លៃគម្រោងបានកត់សម្គាល់លើការផ្លាស់ប្ដូរដ៏វិជ្ជមានជារៀងរាល់ឆ្នាំនៃការវិវឌ្ឍន៍របស់គម្រោងឈេន ៖ កន្លែងដែលពីមុនផ្ដោតតិចតួចលើវិស័យសាកវប្បកម្ម ប៉ុន្តែបច្ចុប្បន្នវិស័យសាវប្បកម្មមានការរីកលូតលាស់ជាថាមវន្ត នៅក្នុងបណ្ដាខេត្តគោលដៅទាំងនោះ។



## បទពិសោធន៍ការផ្សារភ្ជាប់អាជីវកម្មអាជីវកម្មរបស់គម្រោងឈេន



### កសិករ

លោកពូ ចាវ យ៉ុម ជាកសិករអាជីព ដែលមានទីលំនៅ នៅភូមិអូររន់ នៃខេត្តឧត្តរមានជ័យ។ គាត់បានរៀបរាប់ថា ឈេនគឺជា "មេអណ្ដើក" ជាអ្នករៀបចំផ្សំផ្គុំកូនកម្លោះ កូនក្រមុំដើម្បីរៀបការ។ ដោយសារត្រូវបានផ្សំផ្គុំដោយឈេន លោកពូ ចាវ យ៉ុម និងសមាជិកក្រុមកសិកររបស់គាត់បានជួបប្រជុំគ្នាជាទៀងទាត់ដើម្បីពិភាក្សាអំពីអ្វីៗដែលពួកគេចង់ធ្វើ។ ពួកគេព្រមព្រៀងលើបរិមាណផលិតកម្ម និងកាលបរិច្ឆេទប្រមូលផលដើម្បីធានានូវការផ្គត់ផ្គង់ជាប្រចាំទៅកាន់ទីផ្សារក្នុងខេត្ត។ គាត់មានប្រសាសន៍ថា "ការជួញដូរនៅជិតគឺប្រសើរជាងការជួញដូរនៅឆ្ងាយ" ដូច្នេះគាត់ និងក្រុមសមាជិករបស់គាត់ពេញចិត្តសហការជាមួយអាជីវករក្នុងមូលដ្ឋានដែលពួកគេទុកចិត្ត ក្នុងនោះអាជីវករមួយចំនួនពួកគេបានជួបតាមរយៈឈេន។ ពួកគេក៏បានទិញជាក្រុមពីអ្នកលក់ធាតុចូលកសិកម្ម៖

*"ពីមុនពួកយើងទិញគ្រាប់ពូជក្នុងបរិមាណតិចតួច ប៉ុន្តែឥឡូវពួកយើងបានសួរនាំគ្នាមុនពេលបញ្ជាទិញអ្វីៗ។ យើងអាចទិញគ្រាប់ពូជជាកញ្ចប់ធំជាងពីមុន និងទទួលបានតម្លៃធូរថ្លៃជាជាងទិញម្នាក់ៗ ហើយយើងអាចបែងចែកធាតុចូលទាំងនោះក្នុងចំណោមគ្នាយើងបានយ៉ាងងាយស្រួល។"*



## អាជីវករទិញបន្លែ

អ្នកស្រី វ៉ាត់ សុភាព គឺជាអាជីវករប្រមូលទិញបន្លែនៅក្នុងខេត្តឧត្តរមានជ័យ និង ទាក់ទងជាទៀងទាត់ ជាមួយក្រុមកសិករមួយចំនួនដែលគាំទ្រដោយគម្រោង។ ទំនាក់ទំនងទាំងនេះបានចាប់ផ្តើមនៅក្នុងកិច្ចប្រជុំផ្សារភ្ជាប់អាជីវកម្មទៅអាជីវកម្មរបស់គម្រោងឈេន នៅអំឡុងពេលដែលក្រុមកសិករ អ្នកលក់ធាតុចូលកសិកម្ម និង អាជីវករ អង្គុយជុំគ្នាបង្កើតផែនការដាំដុះ និងផែនការអាជីវកម្ម។ គាត់មានប្រសាសន៍ថា “ចំណុចចាប់ផ្តើម ខ្ញុំបានសួរកសិករគ្រប់គ្នាអំពីដំណើរការផលិតកម្ម ថាតើពួកគេផលិតអ្វី នរណាកំពុងចាប់ផ្តើមរៀបចំដីដាំដុះ ហើយធ្វើអ្វីបន្តទៀត។ ” បច្ចុប្បន្ន ខ្ញុំរៀបចំកាលវិភាគទៅតាមមុខបន្លែ ទៅតាមពេលវេលាដែលខ្ញុំត្រូវការ ហើយខ្ញុំពិភាក្សាវាជាមួយក្រុមកសិករផលិតនីមួយៗដោយក្តីស្មោះត្រង់។ នេះគឺជាវិធីដែលខ្ញុំប្រាកដថា នឹងមានបន្លែគ្រប់គ្រាន់សម្រាប់ប្រមូលទិញជាប្រចាំ។ ក្រុមកសិករបានមើលឃើញគុណសម្បត្តិនៃការសហការណ៍ជាមួយអ្នកស្រី សុភាព និងបានលើកឡើងថា៖

*“យើងផ្លាស់ប្តូរគំនិតគ្នាក្នុងអំឡុងពេលកិច្ចប្រជុំនានា ហើយអ្នកស្រីសុភាពបានជួយក្រុមពួកយើងក្នុងការសម្រេចថាដំណាំអ្វីដែលយើងគួរដាំ ដូច្នេះពួកយើងមិនដាំជាន់គ្នាក្នុងពេលតែមួយ។ យើងទាំងអស់គ្នាលក់បន្លែទៅកាន់អ្នកស្រីពីព្រោះគាត់តែងតែមកចូលរួមប្រជុំពិភាក្សាជាមួយពួកយើង។ ”*



## អាជីវករទិញបន្លែ

អ្នកស្រី យស់ សុធីតា អាយុ ៣៥ឆ្នាំ ជាម្តាយដែលមានកូនពីរនាក់ និងរស់នៅក្នុងក្រុងស្ទឹងត្រែង។ រយៈពេលពីរបីឆ្នាំមុន អ្នកស្រីជាគ្រូបង្រៀន ប៉ុន្តែគាត់ត្រូវបានជំរុញទឹកចិត្តពីអ្នកលក់ធាតុចូលកសិកម្មម្នាក់ទៀតអោយបង្កើតតូបលក់ដូរមួយ។ តាមរយៈការចូលរួមកិច្ចប្រជុំផ្សារភ្ជាប់អាជីវកម្មទៅអាជីវកម្មរបស់គម្រោងឈេន អ្នកស្រីបានរៀនសូត្រ និងបានយល់ដឹងនូវអ្វីជាតម្រូវការរបស់កសិករ និងធាតុចូលអ្វីខ្លះដែលត្រូវលក់ ហើយគាត់បានផ្លាស់ប្តូរបទពិសោធន៍ និងទំនាក់ទំនងលម្អិតជាមួយកសិករជាច្រើន។

*“ខ្ញុំបានលក់សម្ភារ និងឧបករណ៍ជាច្រើនរួចមកហើយ ប៉ុន្តែពេលចូលរួមជាមួយគម្រោងឈេន នាងខ្ញុំទទួលបានជោគជ័យខ្ពស់បំផុតពេញមួយឆ្នាំ ជាចំបងកសិករជាច្រើនស្គាល់ខ្ញុំតាមរយៈឈេនតាំងពីឈេនបានចូលមកដល់ទីនេះ ហើយកសិករជាច្រើនកំពុងដាំដុះបន្លែ ដូច្នេះខ្ញុំមានអតិថិជនជាច្រើន។ ”*

អ្នកស្រីធីតាបច្ចុប្បន្នធ្វើការយ៉ាងជិតស្និទ្ធជាមួយបណ្តាញរបស់ក្រុមហ៊ុនជាច្រើនដែលមាននៅក្នុងតំបន់ ដូចជាក្រុមហ៊ុនគ្រាប់ពូជអ៊ីសវេស អង្គរហ្វ្រេីន និងឥន្ទ្រីបៃតង ដែលអ្នកស្រីអាចរកបានប្រភពធាតុចូលកសិកម្មច្រើនប្រភេទ រួមមានប្រព័ន្ធស្រោចស្រព គ្រាប់ពូជ ជីកសិកម្ម ថ្នាំសម្លាប់សត្វល្អិត សំណាញ់ទ្រើង កៅស៊ូគ្របរង និងថាសបណ្តុះកូន។



## បុគ្គលិកដៃគូ និងអ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្ម

កញ្ញា សូរ ចន្ថា ជាបុគ្គលិកមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្ទឹងត្រែង បានក្លាយជាអ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្មតាំងពីគម្រោងឈេនវគ្គ១ និងជារឿយៗបានចែករំលែកចំណេះដឹង និងបទពិសោធន៍របស់គាត់ ជាមួយអ្នកសម្របសម្រួលដទៃទៀត។ កញ្ញាបានបញ្ជាក់ថាគាត់បានចូលរួមនៅក្នុងគម្រោងអភិវឌ្ឍន៍មួយចំនួនទៀតដែលផ្តោតចំបងលើផលិតកម្មដំណាំ និងទ្រឹស្តីកសិកម្ម ដោយមិនបានផ្តល់ឱកាសរៀនសូត្រអនុវត្តជាក់ស្តែងទេ។ បទពិសោធន៍របស់គាត់ជាមួយគម្រោងឈេន គឺមានភាពខុសគ្នាយ៉ាងច្រើន។ វិធីសាស្រ្តអាជីវកម្មទៅអាជីវកម្ម បានផ្តល់ការបណ្តុះបណ្តាលតាមរយៈការអនុវត្តជាក់ស្តែងក្នុងការរៀបចំផែនការផលិត-កម្មរួមគ្នាជាមួយក្រុមកសិករ និងការចរចាសម្របសម្រួលអាជីវកម្មជាមួយតួអង្គទីផ្សារផ្សេងៗជាច្រើន។

ចន្ថាបានលើកឡើងថា *“ការងាររបស់ខ្ញុំជាអ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្ម បានទទួលប្រយោជន៍មិនត្រឹមតែកសិករដែលខ្ញុំសហការជាមួយនោះទេ ប៉ុន្តែក៏បានអភិវឌ្ឍជំនាញផ្ទាល់ខ្លួនផងដែរ។”* ហេតុដូច្នេះហើយ កញ្ញាបានបញ្ចូលគំនិតអាជីវកម្មទៅអាជីវកម្មចូលទៅក្នុងការអនុវត្តសកម្មភាពការងាររបស់គាត់នៅឯមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ កញ្ញាបានបន្ថែមទៀតថា *“ពាក្យថា អាជីវកម្មទៅអាជីវកម្ម បានក្លាយជាពាក្យដែលពេញនិយមក្នុងចំណោមសហគមន៍កសិកម្មកម្ពុជាជាច្រើន។”*

# ៤. ជំហាននៃអាជីវកម្មទៅអាជីវកម្ម

តារាងខាងក្រោម បង្ហាញជាសង្ខេបនូវវិធីសាស្ត្រអាជីវកម្មទៅអាជីវកម្មទាំង៨ជំហាន ដោយមានបញ្ចូលគោលបំណង និងលទ្ធផលនៃជំហាននីមួយៗ៖

| | ជំហានវិធីសាស្ត្រ | គោលបំណង | លទ្ធផល |
|---|---|---|---|
| ១ | ប្រមូលព័ត៌មានទីផ្សារ | យល់ដឹងតម្រូវការទីផ្សារនៅក្នុងតំបន់គោលដៅរបស់គម្រោង រួមមានកត្តាមួយចំនួនដូចជា ទំហំ តម្លៃ គុណភាព ពូជ និងរដូវកាលដាំដុះ។ | • ការសិក្សាទីផ្សារ |
| ២ | ការវិភាគព័ត៌មានទីផ្សារ | យល់ដឹងភាពខុសគ្នារវាងតម្រូវការទីផ្សារ និងការផ្គត់ផ្គង់ រួមមាន ទាំងផលិតកម្មលើសតម្រូវការទីផ្សារ ទាំងកង្វះផលិតកម្ម។ បង្កើតបញ្ជី "ដំណាំសំខាន់ៗ" (Top Crops) សម្រាប់តំបន់របស់គម្រោង ដោយការបែងចែកតាមភូមិសាស្ត្រ។[១] | • ការប្រៀបធៀប តម្រូវការ និងការផ្គត់ផ្គង់<br>• បញ្ជី "ដំណាំសំខាន់ៗ" |
| ៣ | រៀបចំកិច្ចប្រជុំក្រុមកសិករ[២] | កំណត់វិធីប្រសើរបំផុតដើម្បីសម្របសម្រួលក្រុមកសិករពិនិត្យព័ត៌មានទីផ្សារ និងសម្រេចចិត្តលើផែនការផលិតកម្មជាក្រុម និងផែនការអាជីវកម្ម (ទាំងជាបុគ្គល និងជាក្រុម)។ | • សៀវភៅមគ្គុទេ្ទសក៍ការសម្របសម្រួលធ្វើផែនការក្រុមកសិករ<br>• សម្ភារជំនួយដើម្បីចែករំលែកព័ត៌មានទីផ្សារ<br>• គំរូផែនការផលិតកម្ម<br>• គំរូផែនការអាជិវកម្ម |
| ៤ | ផ្គូផ្គងកសិករ ជាមួយទីផ្សារ | ណែនាំកសិករទៅកាន់ទីផ្សារនានា និងបង្ហាញពួកគេ អោយស្វែងយល់អំពីគំរូអាជីវកម្មផ្សេងៗគ្នា និងទំនាក់ទំនងអាជីវកម្មទាំងនោះ។ | • ទស្សនកិច្ចទៅកាន់ក្រុមហ៊ុនប្រមូលទិញបន្លែ<br>• ការពិភាក្សាបឋម ជាមួយតួអង្គទីផ្សារ |
| ៥ | អនុវត្តន៍កិច្ចប្រជុំក្រុមកសិករ | បង្ហាញព័ត៌មានទីផ្សារទៅកាន់កសិករនៅក្នុងក្រុមដែលបានបង្កើត និងសម្របសម្រួលដំណើរការតាមរយៈកសិករដែលយល់ព្រមលើការរៀបចំផែនការផលិតកម្មរួមគ្នា និងផែនការអាជីវកម្មជាក្រុម និងជាបុគ្គលដែលពាក់ព័ន្ធ។ | • ផែនការផលិតកម្មក្រុមកសិករ<br>• ផែនការអាជីវកម្មជាក្រុម និងជាបុគ្គល |
| ៦ | សម្របសម្រួលផែនការផលិតកម្ម | ធានាថាក្រុមកសិករដាំដុះដំណាំអ្វីដែលទីផ្សារត្រូវការ | • ផែនការផលិតកម្មក្រុមកសិករ |
| ៧ | សម្របសម្រួលកិច្ចព្រមព្រៀង | សម្របសម្រួលកិច្ចព្រមព្រៀង ផ្លូវការ និងក្រៅផ្លូវការ រវាងក្រុមកសិករ និងតួអង្គទីផ្សារនានា រួមមានអាជិវករ និងអ្នកលក់ចូលកសិកម្មបញ្ចូលតួអង្គទីផ្សារនៅក្នុងកិច្ចព្រមព្រៀងសហវិនិយោគដើម្បីកាត់បន្ថយហានិភ័យ ហើយជំរុញការវិនិយោគតាមខ្សែច្រវាក់ផ្គត់ផ្គង់។។ | • កិច្ចព្រមព្រៀង (ផ្លូវការ និងមិនផ្លូវការ) រវាងកសិករ និងតួអង្គទីផ្សារដទៃទៀត<br>• ការពិភាក្សាបឋម ជាមួយតួអង្គទីផ្សារ |
| ៨ | តាមដាន | ផ្តល់ការគាំទ្របន្ថែម និងវិភាគ ដោះស្រាយបញ្ហាក្រុមកសិករ និងតួអង្គទីផ្សារដទៃទៀត ដោយផ្សារភ្ជាប់ក្នុងទំនាក់ទំនងអាជីវកម្មទៅអាជីវកម្មជាមួយក្រុមកសិករ។ | • របាយការណ៍វឌ្ឍនភាពក្រុមកសិករ<br>• របាយការណ៍វឌ្ឍនភាព កិច្ចព្រមព្រៀង និង សហវិនិយោគ |

[១] "ដំណាំសំខាន់ៗ" សំដៅលើដំណាំដែលមានតម្រូវការខ្ពស់ហើយសមស្របសម្រាប់កសិករផលិត។

[២] ដំណើរការ បង្កើតក្រុមកសិករ និងដំណើរការធ្វើការជាមួយពួកគេតាមពេលវេលា ត្រូវបានគ្របដណ្តប់នៅក្នុងសៀវភៅមគ្គុទេសក៍របស់គម្រោងឈេនដទៃទៀត។

[៣] ផែនការផលិតកម្ម គឺជាផែនការក្រុម ដែលចង្អុលបង្ហាញថាកសិករមួយណាត្រូវដាំដំណាំមួយណា ហើយដាំនៅពេលណា ដោយរួមបញ្ចូលទំហំដីប៉ុណ្ណាត្រូវបែងចែកដាំដំណាំនីមួយៗ។ ផែនការអាជីវកម្មគ្របដណ្តប់ការវិនិយោគ និងហិរញ្ញវត្ថុ និងអាចជាបុគ្គលក៏បាន (ឧទាហរណ៍៖ កសិករម្នាក់វិនិយោគលើប្រព័ន្ធស្រោចស្រព) ឬជាក្រុមក៏បាន (ឧទាហរណ៍៖ កសិករមួយក្រុមទិញធាតុចូលជាកញ្ចប់រួមគ្នា ដើម្បីទទួលបានតម្លៃធូរថ្លៃ)។

# ៥. សេចក្តីណែនាំជាជំហាន។

## ៥.១ ប្រមូលព័ត៌មានទីផ្សារ

ការយល់ដឹងតម្រូវការនៅក្នុងតំបន់គោលដៅរបស់គម្រោង គឺជាការចាំបាច់សម្រាប់គម្រោងអភិវឌ្ឍន៍ពាណិជ្ជកម្មនានា។

- តើទីផ្សារមូលដ្ឋានមានដំណើរការយ៉ាងដូចម្តេច ?
- តើអ្វីទៅជាភាពបរាជ័យរបស់ពួកគេ ?
- តើព័ត៌មានទីផ្សារបច្ចុប្បន្នដែលពឹងពាក់បាន អាចបញ្ជ្រាបទៅដល់គ្រប់តួអង្គនៅតាមខ្សែច្រវាក់តម្លៃដោយរបៀបណា ?
- តើកសិករអាចទទួលព័ត៌មានតម្រូវការបានសុក្រិតយ៉ាងដូចម្តេច ( ដូចជា៖ ទំហំ ប្រភេទ តម្លៃ និង រដូវកាលនៃតម្រូវការ ) ?



ខណៈពេលមានមធ្យោបាយមួយចំនួនក្នុងការស្វែងរកព័ត៌មានទាំងនេះ គម្រោងឈេនសូមណែនាំថា អ្នកត្រូវបណ្តុះបណ្តាលក្រុមការងាររបស់អ្នកដើម្បីប្រមូលព័ត៌មានទាំងនោះ តាមរយៈទៅជួប និងសម្ភាសន៍អាជីវករដោយផ្ទាល់នៅលើទីផ្សារ។ គោលបំណងសម្រាប់ក្រុមគឺស្វែងយល់តម្រូវការទីផ្សារអោយបានប្រសើរ និងបង្កើតទំនាក់ទំនងជាមួយអ្នកទិញនៅឯទីផ្សារទាំងនោះ។[៤]

ដើម្បីចងក្រងព័ត៌មានទាំងនេះ ក្រុមការងាររបស់អ្នកចាំបាច់ត្រូវសួរអាជីវករអំពីបន្លែ ដែលអ្នកទិញមានតម្រូវការខ្ពស់បំផុត ហើយអាចផលិតបានដោយកសិករ និងទទួលបានផលចំណេញប្រសើរ។ ការស្ទង់មតិទាំងនេះ គួរត្រូវបានអនុវត្តន៍មុនពេលរដូវកាលដាំដុះនីមួយៗ (អាស្រ័យទៅតាមមុខដំណាំ និង/ឬ ទីតាំង) ដើម្បីស្វែងយល់តម្រូវការបន្លែដែលអ្នកទិញរំពឹងទុក។ ក្រុមការងារគម្រោងឈេន បានអនុវត្តន៍ការស្ទង់មតិតួអង្គទីផ្សារពីរដងក្នុងមួយឆ្នាំ គឺនៅក្នុងខែមិថុនា និងខែធ្នូ។ ការស្ទង់មតិជាញឹកញាប់ នឹងផ្តល់ព័ត៌មានជូនអ្នកកាន់តែសុក្រិត ប៉ុន្តែបើស្ទង់មតិញឹកញាប់ពេក អាចមានភាពពិបាកសម្រាប់ក្រុមក្នុងការគ្រប់គ្រង និងអាចជាបន្ទុករំខានដល់អាជីវករ។ គម្រោងឈេន សូមស្នើអោយធ្វើការស្ទង់មតិជាគំរូតំណាងអាជីវករបន្លែ ដើម្បីប្រមូលការស្វែងយល់ជាក់លាក់នូវតម្រូវការបន្លែមូលដ្ឋាន ដោយធ្វើការរួមបញ្ចូលអាជីវករខ្នាតតូច មធ្យម និងខ្នាតធំ ទាំងអ្នកលក់ដុំ និងអ្នកលក់រាយ។[៥]

ការស្ទង់មតិអាជីវករ នឹងផ្តល់អោយក្រុមការងាររបស់អ្នកនូវព័ត៌មានផ្នែកតម្រូវការទីផ្សារ គឺបរិមាណបន្លែដែលអាជីវករមានបំណងទិញពីកសិករ។ ជាងនេះទៅទៀត អ្នកនឹងត្រូវការចាំបាច់នូវព័ត៌មានផ្នែកផ្គត់ផ្គង់ គឺព័ត៌មានអំពីបន្លែដែលត្រូវផលិតដោយកសិករ រួមមានមុខដំណាំ និងពូជអ្វីដែលពួកគេត្រូវជ្រើសរើសនៅពេលពួកគេចាប់ផ្តើមដាំ និងប្រមូលផល ព្រមទាំងទំហំបរិមាណដែលពួកគេមានបំណងផលិត។

> ព័ត៌មានទាំងនេះអាចរកបានពីទីភ្នាក់ងាររដ្ឋាភិបាលថ្នាក់ក្រោមជាតិ (ឧទាហរណ៍៖ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលពាក់ព័ន្ធ)។ ប្រសិនបើមិនមាន អ្នកប្រហែលត្រូវធ្វើការស្ទង់មតិកសិករនៅតំបន់គោលដៅដោយផ្ទាល់។

នៅពេលស្ទង់មតិអាជីវករ ព្យាយាមទទួលអោយបាននូវការព្យាករណ៍ដោយការសួរសំណួរឆ្ពោះទៅមុខ ដូចជា “តើអ្នកគិតថាអ្វីដែលអ្នកនឹងចាំបាច់ត្រូវទិញពីកសិករនៅរដូវកាលនេះ?” ចំណែកនៅពេលស្ទង់មតិកសិករ អ្នកត្រូវសួរសំណួរថយក្រោយដោយផ្អែកលើការចងចាំរបស់ពួកគេដូចជា “តើអ្នកដាំអ្វីឆ្នាំមុនក្នុងអំឡុងពេលរដូវកាលនេះ?”

[៤] ទោះបីយើងផ្តល់អនុសាសន៍ថា ក្រុមការងាររបស់គួរអនុវត្តការស្ទង់មតិដោយផ្ទាល់ អ្នកប្រហែលជាអាចជ្រើសរើសវិធីជួលក្រុមការងារពីខាងក្រៅ ដើម្បីអនុវត្តការសិក្សាទីផ្សារជំនួសអ្នក។ ប្រសិនអ្នកធ្វើដូច្នេះ ការសិក្សាទីផ្សារគួរប្រមូលទាំងព័ត៌មានតម្រូវការ និងការផ្គត់ផ្គង់។ សូមមើលផ្នែក ៥.២។

[៥] អាជីវករលក់ដុំបន្លែលក់ទៅកាន់អាជីវករដទៃទៀត ខណៈដែលអាជីវករលក់រាយលក់បន្តផ្ទាល់ទៅកាន់អ្នកបរិភោគ។ អាជីវករមួយចំនួនដើរតួនាទីទាំងពីរ។

**ខាងក្រោមជាជំហានដែលអាចអនុវត្តន៍តាមបានដើម្បីប្រមូលព័ត៌មានទីផ្សារ។ ជំហានទាំងនេះអនុវត្តន៍បានទាំងពីរគឺ ព័ត៌មានផ្នែកផ្គត់ផ្គង់ និងតម្រូវការទីផ្សារ៖**

១. ធ្វើការជាក្រុម ពិភាក្សា និងព្រមព្រៀងលើគោលបំណងជាក់លាក់សម្រាប់ការស្ទង់មតិ។ វិធីនេះនឹងជួយអ្នកកំណត់វិធីសាស្ត្រស្ទង់មតិត្រឹមត្រូវ រួមមានវិធីជ្រើសរើសសំណាក ទំហំសំណាកជ្រើសរើស និងបញ្ជីសំណួរ។

២. ផ្ទេរការងារទៅសមាជិកក្រុមការងារម្នាក់ ឬច្រើននាក់ដើម្បីបង្កើតវិធីសាស្ត្រស្ទង់មតិ។ (សូមមើលឧបសម្ព័ន្ធទី១ ទី២ និងទី៣ សម្រាប់ឧទាហរណ៍នៃវិធីសាស្ត្រ ការប៉ាន់ស្មានទំហំសំណាកជ្រើសរើស និងបញ្ជីសំណួរស្ទង់មតិ។)

៣. បណ្តុះបណ្តាលក្រុមការងារលើវិធីសាស្ត្រ និងបញ្ជីសំណួរស្ទង់មតិដោយដើរតួសម្តែង។

៤. អនុវត្តការស្ទង់មតិ ទៅតាមវិធីសាស្ត្រដែលបានជ្រើសរើសកាន់តែឆាប់កាន់តែប្រសើរ។

៥. បញ្ចូលទិន្នន័យទៅក្នុងតារាងឌីជីថលដូចជា តារាង Excel និង Google ។ បញ្ចូលទិន្នន័យទាំងនេះអោយបានឆាប់បន្ទាប់ពីប្រមូលបាន ខណៈដែលការចងចាំរបស់អ្នកស្ទង់មតិនៅចាំបានល្អ ព្រមទាំងអាចឆ្លើយនូវសំណួរតាមដាននានាអំពីទិន្នន័យ។



# ព័ត៌មានជំនួយ

**១.** អាជីវករជាធម្មតារវល់ និងប្រហែលជាមិនមានពេលច្រើនឆ្លើយនូវសំណួរស្ទង់មតិវែងនោះទេ ដូច្នេះត្រូវរក្សាសំណួរកាន់តែខ្លីកាន់តែប្រសើរ។ អ្នកអាចពិចារណាធ្វើការស្ទង់មតិនៅពេលដែលអាជីវករមិនសូវរវល់ ហើយបត់បែនទៅតាមកាលៈទេសៈ។

**២.** ជាដំបូងអ្នកគួរធ្វើតេស្តលើបញ្ជីសំណួរស្ទង់មតិទៅកាន់អាជីវករក្នុងចំនួនតិចតួចសិន បន្ទាប់មកកែតម្រូវលើការស្ទង់មតិនេះមុនពេលប្រើប្រាស់ទូលំទូលាយទៅកាន់ទំហំសំណាកគំរូដែលបានកំណត់ទាំងអស់។

**៣.** អាជីវករមួយចំនួនមិននៅមួយកន្លែងទេ ដោយរវល់លក់នៅទីតាំងច្រើន (ដែលខុសពីតូបថេរនៅក្នុងផ្សារ)។ ដើម្បីសម្ភាសន៍អាជិវករទាំងនេះ ក្រុមការងារប្រហែលជាចាំបាច់គួរធ្វើការណាត់ទុកជាមុន។

**៤.** ការប្រមូលព័ត៌មានទីផ្សារពីអាជីវករ គឺជាជំហានដំបូងដែលល្អដើម្បីធ្វើការជាមួយកសិករក្នុងការសម្រេចចិត្តផលិតផ្អែកទៅលើទីផ្សារ។ ទោះជាយ៉ាងណាក៏ដោយ យូរៗទៅ វាមាននិរន្តរភាពជាងការផ្សារភ្ជាប់កសិករជាមួយអាជីវករដោយផ្ទាល់ ដូច្នេះពួកគេអាចតាមដានតម្រូវការទីផ្សារដោយឯករាជ្យជាមួយបុគ្គលិកគម្រោង។

**៥.** សួរទៅកាន់អាជីវករ ថាតើពួកគេមានចំណាប់អារម្មណ៍ចែករំលែកពត៌មានឬលេខទំនាក់ទំនងផ្ទាល់ខ្លួនជាមួយកសិករ ឬអ្នកលក់ធាតុចូលកសិកម្មដទៃទៀតឬទេ។ បង្កើតមូលដ្ឋានទិន្នន័យ (database) ព័ត៌មានអាជីវករដែលប្រហែលជាមានប្រយោជន៍សម្រាប់ការអភិវឌ្ឍបណ្តុំអាជីវកម្មនៅពេលក្រោយ។

# ៥.២ វិភាគព័ត៌មានទីផ្សារ

## ប្រសិនក្រុមការងារអ្នកបានប្រមូលព័ត៌មានទីផ្សារតាមរយៈបញ្ជីសំណួរស្ទង់មតិគ្រប់ជ្រុងជ្រោយហើយ អ្នកចាំបាច់ត្រូវធ្វើការវិភាគ និងសម្រេចថាតើត្រូវបង្ហាញទៅកសិករយ៉ាងដូចម្តេច។

**គោលបំណងនៃការវិភាគគឺ (១) ជួយក្រុមការងារអ្នកអោយយល់អំពីទីផ្សារដែលអ្នកកំពុងធ្វើការនៅទីនោះ និង (២) ជួយកសិករអោយយល់អំពីទីផ្សារ និងសម្រេចចិត្តបានប្រសើរថាតើមុខដំណាំអ្វីដែលត្រូវដាំ ក្នុងបរិមាណប៉ុណ្ណា និងនៅពេលណា។**




សម្រាប់ជំហានបន្ទាប់ គម្រោងឈេនណែនាំអោយមានការគិតគូរលើមុខដំណាំសំខាន់ៗ គឺជាភាពចាំបាច់ និងមានសារៈប្រយោជន៍ខ្លាំង។ ដំណាំសំខាន់ៗ អាចត្រូវបានកំណត់ជាដំណាំដែលមានតម្រូវការខ្ពស់ ហើយសមប្រកបសម្រាប់កសិករក្នុងការផលិត។ ការកំណត់អត្តសញ្ញាណដំណាំសំខាន់ៗ អាចគិតពិចារណាលើកត្តាបន្ថែមដូចជា តម្លៃលក់ ថ្លៃដើម និងភាពងាយស្រួលក្នុងផលិតកម្ម តម្លៃអាហារូបត្ថម្ភ និងជាយុទ្ធសាស្ត្រកសិកម្មអាទិភាពរបស់រដ្ឋាភិបាល។

ជាការប្រសើរ ការវិភាគគួរត្រូវបានអនុវត្តដោយក្រុមការងារគម្រោង ប៉ុន្តែអាស្រ័យលើពេលវេលា និងធនធានមនុស្សដែលមានស្រាប់ គម្រោងប្រហែលមានជម្រើសជួលទីប្រឹក្សាពីខាងក្រៅ។ លទ្ធផលនៃការវិភាគ អាចបោះពុម្ពផ្សាយ និងអាចបង្ហាញជាកាតព័ត៌មានមួយសម្រាប់កសិករ រួមមាន តម្លៃប៉ាន់ស្មានក្នុងមួយមុខដំណាំ បរិមាណតម្រូវការរបស់អាជីវករក្នុងមួយមុខដំណាំ បរិមាណផ្គត់ផ្គង់របស់ក្រុមកសិករក្នុងមួយមុខដំណាំ តំបន់ដាំដុះដំណាំ និងកសិករសកម្មក្នុងមួយមុខបន្លែ ព្រមទាំងតម្រូវការ និងការផ្គត់ផ្គង់ក្នុងមួយមុខបន្លែផងដែរ។

### គម្រោងឈេនផ្តល់យោបល់នូវជំហានដូចខាងក្រោមដើម្បីវិភាគព័ត៌មានទីផ្សារ៖

១. ធ្វើការកំណត់ថាតើព័ត៌មានសំខាន់អ្វីខ្លះដែលអ្នកចង់បង្ហាញទៅកសិករ។ គម្រោងឈេនផ្តល់យោបល់អោយបង្ហាញតែព័ត៌មានដំណាំសំខាន់ៗដែលពាក់ព័ន្ធ ដើម្បីកាត់បន្ថយព័ត៌មានច្រើនពេកនៅពេលត្រូវពិភាក្សា។

២. សម្រេចចិត្តអំពីវិធីត្រូវបង្ហាញព័ត៌មានទៅកសិករ និងរៀបចំសម្ភារជំនួយការមើលដែលត្រូវគ្នានឹងព័ត៌មាន។ វិធីនេះអាចបញ្ចូលព័ត៌មានសរសេរដោយដៃនៅលើក្រដាសផ្ទាំងធំ ព្រីនផ្ទាំងរូបភាពដែលពាក់ព័ន្ធ ឬឯកសារចែកជូនតូចៗសម្រាប់ម្នាក់ៗ។

៣. ធ្វើការជាក្រុម ពិភាក្សាអំពីមុខដំណាំដែលពួកគេបានដាំកាលពីឆ្នាំមុន និងខែអាចបន្លែជន់ប្រសិនបើកសិករសម្រេចចិត្តដាំដុះដំណាំដូចគ្នា។ ការជន់គឺនៅពេលដែលការផ្គត់ផ្គង់បន្លែលើសពីតម្រូវការទីផ្សារ។ វាមានសារៈសំខាន់ ក្នុងការផ្តល់ដំបូន្មានទៅកសិករអំពីការជន់នេះ និងពិភាក្សាជម្រើសផែនការផលិតកម្មជាមួយពួកគេ។

៤. ធ្វើការជាក្រុម ពិភាក្សាអំពីមុខដំណាំ និងខែដែលទំនងអាចជួបប្រទះនឹងការខ្វះខាត។ ការខ្វះខាត គឺនៅពេលការផ្គត់ផ្គង់បន្លែមិនគ្រប់គ្រាន់ទៅតាមតម្រូវការទីផ្សារ។ វាមានសារៈសំខាន់ក្នុងការជូនដំណឹងទៅកសិករអំពីកង្វះខាតបន្លែនេះ និងបង្ហាញនូវឱកាសអោយពួកគេដាំដំណាំមួយមុខក្នុងបរិមាណច្រើន ឬពួកគេផ្លាស់ប្តូរពេលវេលាផលិតកម្មដើម្បីបំពេញតម្រូវការទីផ្សារ។

សូមមើល**ឧបសម្ព័ន្ធ៤** សម្រាប់ឧទាហរណ៍នៃលទ្ធផលការវិភាគទីផ្សារ។





# ព័ត៌មានជំនួយ

១. នៅពេលបង្ហាញព័ត៌មានទៅកសិករ សូមគិតដល់កម្រិតសមត្ថភាពចំណេះដឹង និងការគណនាតួលេខរបស់កសិករ។ ប្រសិនបើកសិករមួយចំនួនមិនអាចអាន និងសរសេរ ត្រូវជ្រើសរើសការបង្ហាញដែលអាចមើលឃើញដោយធ្វើជាក្រាហ្វមានព៌ណចម្រុះដើម្បីទំនាក់ទំនងព័ត៌មានសំខាន់ៗ។



២. បញ្ជីព័ត៌មានដូចជា តារាង Excel និង Google ផ្តល់ជម្រើសដើម្បីជំនួយការពិនិត្យមើលទិន្នន័យ (ឧទាហរណ៍៖ តារាង (chart) និង ក្រាហ្វជាដើម) ដែលនឹងអាចជួយក្រុមការងារអ្នកក្នុងការវិភាគព័ត៌មានទីផ្សារ។ យ៉ាងណាក៏ដោយ គម្រោងឈេនសូមផ្តល់យោបល់យ៉ាងមុតមាំថា អ្នកត្រូវធ្វើការជាមួយអ្នកជំនាញដើម្បីបង្កើតប្រព័ន្ធជំនួយការពិនិត្យមើលទិន្នន័យ។ ជាការសាកសមប្រព័ន្ធនឹងអនុញ្ញាតអោយអ្នកកែតម្រូវលើជំនួយការពិនិត្យមើលទិន្នន័យផ្អែកលើកត្តាមួយចំនួនដូចជា ឆ្នាំ រដូវកាល មុខដំណាំ ខេត្ត ស្រុក និងភូមិ។

៣. គម្រោងឈេនបានប្រើប្រាស់កម្មវិធី powerful software មានឈ្មោះថា Power BI ដើម្បីវិភាគ និងពិនិត្យមើលទិន្នន័យសម្រាប់ទាំងការរៀនសូត្រខាងក្នុង និងការចែកចាយទៅខាងក្រៅទៅកាន់កសិករនិងភាគីពាក់ព័ន្ធផ្សេងៗ។ មានកម្មវិធីជាច្រើនទៀតដែលសមរម្យសម្រាប់គោលបំណងនេះ ប៉ុន្តែយើងផ្តល់យោបល់ថាអ្នកគួរជ្រើសរើសតែមួយដែលអាបញ្ចូលជាមួយប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃរបស់អ្នកបាន (M&E) ដើម្បីងាយស្រួលធ្វើរបាយការណ៍ទៅម្ចាស់ជំនួយ។

៤. តម្លៃបន្លែមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស ដូច្នេះវាមានភាពលំបាកក្នុងការព្យាករណ៍តម្លៃទិញក្នុង១គីឡូក្រាមនៅលើទីផ្សារជាមុន។ ប៉ុន្តែ យើងអាចសួរទៅអាជីវករដោយផ្ទាល់ថាតើតម្លៃទិញនៃមុខបន្លែនៅក្នុងខែនីមួយៗ “ថ្លៃ” “មធ្យម” ឬ “ចុះថោក”។ ព័ត៌មានសាមញ្ញបែបនេះក៏អាចផ្តល់ការយល់ដឹងដល់កសិករបានប្រសើរផងដែរ អំពីពេលវេលាណាមួយដែលពួកគេអាចរំពឹងបានតម្លៃខ្ពស់សម្រាប់បន្លែជាក់លាក់។



# ៥.៣ រៀបចំកិច្ចប្រជុំក្រុមកសិករ



នៅកិច្ចប្រជុំក្រុមកសិករពេលបន្ទាប់ទៀត អ្នកនឹងបង្ហាញព័ត៌មានទីផ្សារដែលអ្នកប្រមូលបាន និងបានវិភាគតម្រូវការ ការផ្គត់ផ្គង់ ភាពជន់ និងភាពខ្វះខាតនៃបន្លែ ព្រមទាំងការងារជាក្រុមដើម្បីកំណត់នូវផែនការផលិតកម្មសម្រាប់រដូវកាលខាងមុខ។ អ្នកនឹងចូលរួមជាមួយកសិករក្នុងការរៀបចំផែនការអាជីវកម្មផងដែរសម្រាប់ការវិនិយោគទៅលើបច្ចេកវិទ្យា និងការកាត់បន្ថយហានិភ័យ។

## ជំហានជាអនុសាសន៍ត្រូវបានផ្តល់ដូចខាងក្រោម៖

១. ធ្វើការងារជាក្រុម ពិភាក្សា និងព្រមព្រៀងលើគោលបំណងនៃកិច្ចប្រជុំ។ នៅពេលគោលបំណងទាំងនោះត្រូវបានព្រមព្រៀងភ្លាម រៀបចំរបៀបវារៈកិច្ចប្រជុំដែលរំពឹងថានឹងអាចសម្រេចបាន។ សូមមើល**ឧបសម្ព័ន្ធ៥** សម្រាប់គំរូរបៀបវារៈនៃកិច្ចប្រជុំ។

២. សម្រាប់ចំណុចនីមួយៗក្នុងរបៀបវារៈ ត្រូវសម្រេចកំណត់ពេលវេលាដែលគួរចំណាយ នរណាជាអ្នកសម្របសម្រួល ជ្រើសរើសវិធីសាស្ត្រប្រជុំបែបណាដែលប្រសើរបំផុត ហើយថាតើសម្ភារអ្វីខ្លះដែលចាំបាច់។ “វិធីសាស្ត្រប្រជុំ” ប្រហែលជាការដាក់បញ្ចូលគ្នានៃបទបង្ហាញ ការពិភាក្សាក្រុមតូច និងល្បែងកំសាន្ត។ ចំណែក “សម្ភារ” មានដូចជាផ្ទាំងរូបភាព ឯកសារចែកជូន ក្រដាសផ្ទាំងធំ ហ្វឺត ស្កត់ ប៊ិក សៀវភៅកត់ត្រា ទឹក និងអាហារសម្រន់។

៣. បណ្តុះបណ្តាលក្រុមការងារអ្នកអំពីរបៀបអនុវត្តន៍កិច្ចប្រជុំរៀបចំផែនការអាជីវកម្មកសិករ ដោយបង្កើតជាការដើរតួសម្តែងដែលសិក្ខាកាមម្នាក់ដើរតួនាទីជាអ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្ម និងសមាជិកក្រុមដទៃទៀតដើរតួជាក្រុមកសិករ។ សូមមើល**ឧបសម្ព័ន្ធ៦** សម្រាប់ការណែនាំរបៀបដើរតួសម្តែង។

៤. ប្រសិនបើកសិករត្រូវបានស្នើសុំអោយអនុវត្តការរៀបចំធ្វើផែនការផលិតកម្ម និង/ឬផែនការអាជីវកម្មក្នុងអំឡុងពេលនៃកិច្ចប្រជុំ អ្នកគួរត្រូវរៀបចំគំរូឯកសារដែលចាំបាច់មុនពេលកិច្ចប្រជុំ។ សូមមើល**ឧបសម្ព័ន្ធ៧** សម្រាប់ឯកសារគំរូ។

៥. អ្នកដែលនឹងត្រូវសម្របសម្រួលផ្នែកណាមួយនៃរបៀបវារៈ គួរមានឱកាសបង្កើតអោយមានការអនុវត្តដោយដើរតួសម្តែងអោយបានម្តង ឬពីរដង។ ក្នុងអំឡុងពេលការដើរតួសម្តែងនេះ អ្នកដែលនៅសល់អាចដើរតួជាក្រុមកសិករ។



# ព័ត៌មានជំនួយ

១. ស្វែងរកពេលវេលាសមរម្យសម្រាប់ជួបជាមួយកសិករនៅក្នុងភូមិ ពិចារណាពេលវេលាធ្វើដំណើរ រៀបចំអាហារ និងសម្ភារផ្សេងៗទៀត។

២. ជ្រើសរើសទីតាំងកិច្ចប្រជុំដែលបង្ករភាពងាយស្រួល និងសមរម្យសម្រាប់ចំនួនអ្នកចូលរួមដែលបានរំពឹងទុក និងសកម្មភាពទាំងឡាយដែលអ្នកបានរៀបចំ។

៣. ត្រូវប្រាកដថាប្រធានភូមិបានដឹងឮ និងគាំទ្រកិច្ចប្រជុំនេះ។

៤. ប្រសិនបើតំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានពេលវេលា អញ្ជើញពួកគេចូលរួមកិច្ចប្រជុំនេះ។

៥. ក្រៅពីការអញ្ជើញនេះ ផ្ញើរសាររំឭកដើម្បីធានាបាននូវវត្តមានរបស់អ្នកចូលរួម។

៦. សុំអោយអ្នកសម្របសម្រួលដ៏ល្អរបស់អ្នកអនុវត្តន៍អោយបាន២ឬ៣កិច្ចប្រជុំដើម្បីអោយសមាជិកក្រុមដទៃទៀតបានរៀនសូត្រពីឧទាហរណ៍ទាំងនេះ។

៧. សរុបសង្ខេបកិច្ចប្រជុំនីមួយៗ ពិភាក្សានូវអ្វីដែលមានដំណើរការល្អ និងអ្វីដែលត្រូវពង្រឹងបន្ថែម។

៨. ប្រសិនបើបុគ្គលិករបស់អ្នកមិនសូវមានឬគ្មានបទពិសោធន៍ក្នុងការសម្របសម្រួលកិច្ចប្រជុំក្រុមកសិករ ជាបឋមគឺអ្នកគួររៀបចំ "បណ្តុះបណ្តាលគ្រូបង្គោល"។

៩. កិច្ចប្រជុំគួរកុំអោយស៊ីជម្រៅពេក ហើយកិច្ចប្រជុំកាន់តែមានប្រសិទ្ធភាពប្រសិនបើគ្រប់គ្នាមានការកំសាន្តសប្បាយ។ ហេតុដូច្នេះហើយសូមព្យាយាមបញ្ចូលល្បែងកំសាន្ត រឿងខ្លីៗ និងសកម្មភាពរស់រវើក ក្នុងអំឡុងពេលនៃកិច្ចប្រជុំ។

១០. អញ្ជើញអាជីវករ អ្នកលក់ធាតុចូលកសិកម្ម និង/ឬ អ្នកតំណាងបច្ចេកទេសរបស់ក្រុមហ៊ុនឯកជន ដើម្បីចរចាជាមួយកសិករដោយផ្ទាល់អំពីការវិនិយោគផ្នែកធាតុចូល និងបច្ចេកវិទ្យា។

១១. នាំយកកាម៉េរ៉ា និងចាត់តាំងសមាជិកក្រុមការងារដើម្បីថតរូបក្នុងអំឡុងពេលកិច្ចប្រជុំ។



# ៥.៤ ផ្គូផ្គងក្រុមកសិករជាមួយទីផ្សារ

**កសិករភាគច្រើនរស់នៅឆ្ងាយពីទីប្រជុំជន និងមានការយល់ដឹងតិចតួចអំពីទំហំទីផ្សារដែលអាចលក់បានក្នុងមួយថ្ងៃ ថាតើអ្វីទៅជាលក្ខណៈពិសេស និងតម្រូវការគុណភាពនៅទីនោះសម្រាប់ប្រភេទអតិថិជនខុសៗគ្នា ហើយទំហំប៉ុណ្ណាដែលពួកគេគួរផលិតដើម្បីសម្របតាមតម្រូវការទីផ្សារ។**

ហេតុដូច្នេះហើយ មុនពេលប្រជុំជាមួយក្រុមកសិករដើម្បីបង្កើតផែនការផលិតកម្ម និងអាជីវកម្មដំបូង យើងបានដឹកនាំតំណាងក្រុមកសិករនីមួយៗ (២នាក់ក្នុងមួយក្រុម) ទៅទស្សនកិច្ចទីផ្សារមួយចំនួន។ វិធីនេះជួយអោយពួកគេមើលឃើញសកម្មភាពនៅក្នុងផ្សារ សង្កេតមើលប្រភេទបន្លែអ្វីខ្លះកំពុងត្រូវបានដាក់លក់ និងធ្វើការប៉ាន់ស្មានទំហំច្រើនប៉ុណ្ណាដែលអាជីវករអាចលក់បាន ព្រមទាំងលក់បានក្នុងតម្លៃយ៉ាងដូចម្ដេចដែរ។



**គម្រោងឈេនសូមផ្ដល់យោបល់ជាជំហានៗស្ដីពីការផ្គូផ្គងកសិករជាមួយទីផ្សារដូចខាងក្រោម៖**

- ពន្យល់សង្ខេបៗទៅកសិករអំពីជំនាញក្នុងការលក់ផលិតផល និងការបង្កើតកិច្ចព្រមព្រៀងជាមុន។ ចំណេះដឹងមូលដ្ឋាននេះជួយអោយពួកគេមានទំនុកចិត្តក្នុងការនិយាយជាមួយអាជីវករ/អ្នកទិញនៅឯទីផ្សារ។
- រៀបចំការប្រជុំរវាងក្រុមកសិករគោលដៅ និងកសិករណាដែលមានបទពិសោធន៍ច្រើនហើយមានបំណងចង់ចែករំលែក ព្រមទាំងពិភាក្សាអំពីបទពិសោធន៍ក្នុងការធ្វើជំនួញ។ អ្នកសម្របសម្រួលអាជីវកម្ម ទៅអាជីវកម្មអាចសម្របសម្រួលកិច្ចពិភាក្សាបឋមនេះ។
- កំណត់កាលបរិច្ឆេទ និងទីតាំងប្រជុំសម្រាប់ទស្សនកិច្ច។ ដើម្បីជៀសវាងមនុស្សច្រើនពេកនៅទីផ្សារ និងបាំងផ្លូវដើររបស់អាជីវករលក់រាយ កំណត់ចំនួននៃតំណាងកសិករដើម្បីចូលរួមដំណើរទស្សនកិច្ចនេះ ឬបំបែកជាក្រុមតូចៗ។
- នៅពេលទស្សនកិច្ចតូបអាជីវករនីមួយៗ ណែនាំកសិករអោយជួបជាមួយអាជីវករ និងផ្ដល់ពេលអោយពួកគេជជែកលេងជាមួយគ្នា។ កសិករប្រហែលជាចង់សម្ភាសន៍អាជីវករថាតើពួកគេទិញបន្លែពីខាងណា ក្នុងបរិមាណប៉ុណ្ណា និងតម្លៃប៉ុន្មាន ព្រមទាំងថាតើការលក់ដូរមានភាពខុសគ្នាយ៉ាងដូចម្ដេចរវាងថ្ងៃនីមួយៗក្នុង១សប្ដាហ៍ ឬ១ខែ ។ល។
- រំឭកតំណាងក្រុមកសិករអោយធ្វើការកត់ត្រា និងឬធ្វើការកំណត់ចំណាំលើអ្វីដែលពួកគេបានឃើញដើម្បីពួកគេអាចចែករំលែកបទពិសោធន៍ជាមួយក្រុមកសិកររបស់ពួកគេនៅកិច្ចប្រជុំបន្ទាប់។



# ព័ត៌មានជំនួយ

១. អំឡុងពេលទស្សនកិច្ចសិក្សា អនុញ្ញាតអោយកសិករអនុវត្តដោយផ្ទាល់ជាមួយអតិថិជន ក្នុងនាមជាអាជីវករ ដើម្បីពួកគេអាចដកស្រង់បទពិសោធន៍នៃការលក់ទៅកាន់អតិថិជន និងស្វែងយល់អំពីបញ្ហាប្រឈមរបស់អាជីវករ និងតម្លៃបន្ថែមដែលពួកគេនាំយកទៅខ្សែច្រវាក់ផ្គត់ផ្គង់។

២. ប្រសិនបើមិនមានអ្នកលក់ធាតុចូលកសិកម្មនៅក្នុងតំបន់ទេ អញ្ជើញអ្នកលក់ធាតុចូលពីតំបន់ផ្សេងចូលរួមកិច្ចប្រជុំជាមួយកសិករ។ ប្រសិនបើមានដេប៉ូលក់ធាតុចូលកសិកម្មនៅក្នុងខេត្តរៀបចំទស្សនកិច្ចនៅទីនោះដើម្បីកសិករអាចមើលឃើញជម្រើសផ្សេងៗដែលអាចអាស្រ័យបាន។



៣. ប្រសិនបើមានក្រុមហ៊ុនប្រមូលទិញសំខាន់ៗនៅឯភ្នំពេញ អ្នកគួររៀបចំដំណើរទស្សនកិច្ចសិក្សានាំកសិករទៅទីតាំងលក់ដុំ ឬផ្សារទំនើប ជាពិសេសទៅកាន់ស្ថានីយ៍លាងសម្អាត និងវេចខ្ចប់ ដើម្បីមើលថាតើកន្លែងទាំងនោះមានលក្ខណៈ និងដំណើរការយ៉ាងណា ព្រមទាំងដោះស្រាយបញ្ហា សម្អាត និងទុកដាក់ផលិតផលយ៉ាងដូចម្តេចដែរ។

# ៥.៥ អនុវត្តន៍កិច្ចប្រជុំក្រុមកសិករ

**នៅពេលការរៀបចំត្រូវបានបំពេញ ហើយក្រុមកសិករបានត្រៀមខ្លួនរួចរាល់ គឺដល់ពេលវេលាត្រូវកំណត់កាលវិភាគ និងរៀបចំកិច្ចប្រជុំ។ គម្រោងឈេនសូមផ្តល់យោបល់នូវជំហាននីមួយៗដោយផ្អែកទៅលើបទពិសោធន៍ដូចខាងក្រោម៖**

១. មួយថ្ងៃមុនពេលកិច្ចប្រជុំ ពិនិត្យមើលសម្ភារទាំងអស់ ទៅមើលទីតាំងប្រជុំថាតើមានអ្វីចាំបាច់ត្រូវកែតម្រូវដើម្បីបង្ករភាពសមស្របសម្រាប់របៀបវារៈ និងចំនួនអ្នកចូលរួម បញ្ជាក់ទៅអ្នកចូលរួមទាំងអស់តាមទូរស័ព្ទ និងពិនិត្យមើលរបៀបវារៈម្តងទៀតចុងក្រោយជាមួយក្រុមការងារដើម្បីប្រាកដថាគ្រប់គ្នាបានយល់អំពីចក្ខុវិស័យសម្រាប់កិច្ចប្រជុំ ព្រមទាំងតួនាទី និងទំនួលខុសត្រូវរបស់ពួកគេនីមួយៗ។

២. នៅថ្ងៃនៃព្រឹត្តិការណ៍ អ្នកត្រូវមកដល់ទីតាំងមុន៣០នាទីដើម្បីរៀបចំកិច្ចប្រជុំ ដោយត្រៀមអោយមាននូវកន្លែងអង្គុយ អាហារសម្រន់ និងសម្ភារផ្សេងៗជាដើម។ នៅពេលកសិករមកដល់ រាក់ទាក់ស្វាគមន៍ទៅកាន់ពួកគេប្រកបដោយភាពកក់ក្តៅ។ ប្រសិនអាចធ្វើទៅបាន អោយពួកគេអង្គុយជារង្វង់ ឬពាក់កណ្តាលរង្វង់ ដើម្បីពួកគេងាយមើលឃើញគ្នា និងងាយមើលសម្ភារ និងបទបង្ហាញ។ ចាប់ផ្តើមជាមួយពាក្យស្វាគមន៍ និងការណែនាំខ្លួន។ អានរបៀបវារៈដោយសង្ខេប និងគោលបំណងនៃកិច្ចប្រជុំ។

៣. សម្របសម្រួលសកម្មភាពដោយផ្តោតពួកគេលើបំណងប្រាថ្នាគ្រួសារ និងផ្ទាល់ខ្លួន។ វិធីនេះជួយជំរុញលើកទឹកចិត្តពួកគេសម្រាប់បង្កើនចំណូលពីការដាំដុះ។ (យើងបានប្រើប្រាស់លំហាត់មួយមានឈ្មោះថា ការសុបិនលើចំណូល "Income Dream" ដែលក្នុងនោះកសិករបានពណ៌នាអំពីចក្ខុវិស័យ ថាតើពួកគេត្រូវអភិវឌ្ឍអាជីវកម្មបន្លែ និងបង្កើនប្រាក់ចំណូលរបស់ពួកគេដោយរបៀបណា)។

៤. ផ្តល់ព័ត៌មានអំពីបន្លែ និងពន្យល់អំពីហេតុផលដែលវាជាប្រភពសំខាន់ក្នុងការទាញយកប្រាក់ចំណូលជាងការដាំដុះដំណាំសាមញ្ញៗធម្មតាដទៃទៀត ដោយប្រើប្រាស់វិធីវិភាគចំណេញសរុប (Gross Margin) ។ ពិភាក្សាបញ្ហាជួបប្រទះផ្សេងៗមួយចំនួនក្នុងការដាំដុះបន្លែ និងពន្យល់ណែនាំថាការរៀបចំផែនការបានល្អអាចទទួលបានជោគជ័យលើបញ្ហាទាំងនោះ។

៥. ធ្វើការវិភាគចំណូលចំណាយងាយៗសម្រាប់មុខបន្លែនីមួយៗ រួមមានការបង្កើតបញ្ជីសកម្មភាពទាំងអស់ដែលចាំបាច់ដើម្បីដាំដុះបន្លែនៅលើទីតាំងស្តង់ដារមួយ (១០០ម៉ែត្រការ៉េ) ដូចជាការរៀបចំដី តំឡើងកៅស៊ូគ្របរង និងប្រព័ន្ធដំណក់ទឹក បណ្តុះ និងស្ទូងកូនដំណាំ ធ្វើស្មៅ តាក់តែងមែក គ្រប់គ្រងកត្តាចង្រៃ និងប្រមូលផល ហើយបន្ទាប់មកធ្វើបញ្ជីធាតុចូលទាំងអស់ និងឈ្នួលកម្លាំងពលកម្មដែលចាំបាច់សម្រាប់សកម្មភាពនីមួយៗ ព្រមទាំងគណនាថ្លៃដើម។ ពិភាក្សាទិន្នផលរំពឹងទុក និងតម្លៃទីផ្សារនៅចំការជាមធ្យម បន្ទាប់មកធ្វើការប្រៀបធៀបថ្លៃដើមធាតុចូលទាំងអស់ ជាមួយនឹងការលក់សរុប (ទិន្នផលគិតជាគីឡូក្រាម ពីតំបន់ដាំស្តង់ដារ x តម្លៃនៃការលក់ក្នុង១គីឡូក្រាម)។ ការលក់សរុបដកនឹងការចំណាយសរុប ស្មើនឹងចំណេញសរុប។ ប្រៀបធៀបចំណេញសរុបសម្រាប់ដំណាំនីមួយៗក្នុងរដូវផ្សេងគ្នា។ ការណែនាំលម្អិតលើរបៀបវិភាគចំណូលចំណាយបែបនេះ នឹងត្រូវបានផ្តល់នៅក្នុងសៀវភៅមគ្គុទេសក៍ផ្សេងមួយទៀត៖ ការរៀបចំគម្រោងថវិកាលើមុខដំណាំ។

៦. បង្ហាញព័ត៌មានតម្រូវការបន្លែ៖ លើកឡើងនូវការជន់ ជាសញ្ញាត្រូវបន្ថយការដាំដុះបន្លែដែលលើសតម្រូវការទីផ្សារ (ឧទាហរណ៍ត្រសក់)ជាដើម និងបង្ហាញពីកង្វះខាតបន្លែ ដែលជាសញ្ញាតម្រូវដាំបន្លែដទៃទៀតក្នុងបរិមាណច្រើន (ឧទាហរណ៍ ខាត់ណាដើម ប៉េងប៉ោះ និងត្រប់) ជាដើម។

៧. សម្របសម្រួលដំណើរការធ្វើសេចក្តីសម្រេចចិត្តថា តើទីតាំងណាក្រុមកសិករត្រូវជ្រើសរើសដំណាំសំខាន់ៗដែលពួកគេនឹងដាំ។ វាជាការសម្រេចចិត្តជាក្រុមដើម្បីអាចសម្របសម្រួលផែនការផលិតកម្ម។ នៅក្នុងការសម្របសម្រួលផែនការផលិតកម្ម មិនមែនគ្រប់គ្នាដាំមុខដំណាំដូចគ្នាទេ ប៉ុន្តែកសិករដែលដាំមុខដំណាំដូចគ្នាប្រមូលផលក្នុងពេលតែមួយ មិនត្រូវដាំច្រើនពេកក្នុងពេលតែមួយនោះទេ។ មុខដំណាំសំខាន់ៗពឹងផ្អែកលើតម្រូវការទីផ្សារ និងហានិភ័យលើផលិតកម្ម។ (សូមមើលឧបសម្ព័ន្ធ៨សម្រាប់លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសមុខដំណាំសំខាន់ៗ)។ សូមមើលជំហាន 5.6 ផងដែរដែលបង្ហាញលម្អិតស្តីពីផលិតកម្មដំណាំ។



៨. ក្រុមកសិករគួរជ្រើសតាំងអ្នកដឹកនាំក្រុមដែលនឹងជួយសម្របសម្រួលផលិតកម្មក្នុងអំឡុងរដូវដាំដុះខាងមុខ និងដើរតួនាទីជាអ្នកទាក់ទងចំបងជាមួយក្រុមការងារគម្រោង និងសម្រាប់ដៃគូដទៃទៀតដែលមានបំណងធ្វើការជាមួយក្រុម។

៩. នៅពេលការរៀបចំផែនការត្រូវបានបញ្ចប់ ពិនិត្យមើលជំហានបន្ទាប់ជាមួយក្រុមរួមមាន ថាតើនរណានឹងធ្វើអ្វី ធ្វើនៅពេលណា។ ធ្វើការសន្និដ្ឋានព្រឹត្តិការណ៍រួមជាមួយពាក្យលើកទឹកចិត្ត និងការអបអរ។

# ព័ត៌មានជំនួយ




១. រក្សាគម្លាតសង្គម និងវិធានការ ការពារដទៃទៀត គួរត្រូវបានតាមដានប្រសិនបើការរីករាលដាលនៃជំងឺកូវីតនៅតែបន្ត។ ត្រូវធានាថាអ្នកចូលរួមអង្គុយយ៉ាងហោចណាស់ ១,៥ម៉ែត្រពីគ្នា និងចែកម៉ាសការពារដល់ពួកគេ។

២. អ្នកចូលរួមមួយចំនួនប្រហែលយកកូនៗមកជាមួយ ដូច្នេះត្រូវប្រាកដថាអាហារសម្រន់មានគ្រប់គ្រាន់ និងសមរម្យ ព្រមទាំងមានកន្លែងក្មេងលេង។ ចាត់តាំងនរណាម្នាក់អោយគ្រប់គ្រងក្មេងៗក្នុងអំឡុងពេលកិច្ចប្រជុំ។





៣. ប្រសិនបើក្រុមកសិករមានអ្នកដឹកនាំហើយ (ប្រហែលចេញមកពីគំនិតផ្តួចផ្តើមដំបូង) គាត់អាចជួយចាត់ចែងកម្មវិធី អញ្ជើញអ្នកចូលរួម និងផ្តល់ទំនួលខុសត្រូវលើចំណែកណាមួយនៃរបៀបវារៈ។

៤. ជួបជាមួយកសិករមុនពេលកិច្ចប្រជុំក្រុម ដើម្បីស្គាល់ពួកគេម្នាក់ៗ និងបង្កើតទំនាក់ទំនងជាមួយពួកគេ។ ធ្វើការសួរនាំអំពីបទពិសោធន៍ដាំដុះរបស់ពួកគេ បញ្ហាដែលពួកគេជួបប្រទះពីមុន និងក្តីសង្ឃឹមរបស់ពួកគេសម្រាប់ពេលអនាគត។

៥. ប្រើប្រាស់ក្រដាសផ្ទាំងធំដើម្បីបង្កើតផែនការអាជីវកម្ម។ អ្នកដឹកនាំក្រុមគួរដាក់ក្រដាសផ្ទាំងធំនោះនៅកន្លែងណាដែលគ្រប់គ្នាអាចទៅមើលបានងាយស្រួលនៅថ្ងៃក្រោយ។



៦. ធ្វើការជិតស្និទ្ធជាមួយ អ្នកដឹកនាំក្រុម មុនពេល អំឡុងពេល និងក្រោយពេលបង្កើតផែនការអាជីវកម្ម។ អ្នកដឹកនាំនឹងជួយប្រាកដថាកសិករផ្សេងៗទៀតសហការ និងធ្វើការល្អជាមួយគ្នា។

៧. បង្កើតការកសាងទំនុកចិត្ត និងគោលបំណងនៅរៀងរាល់កិច្ចប្រជុំក្រុមកសិករ និងគាំទ្រទំនាក់ទំនងប្រកបដោយការទុកចិត្តគ្នារវាងកសិករ។ ទាំងនេះអាចបញ្ចូលការលើកទឹកចិត្តអោយមានទំនាក់ទំនងបន្ថែមទៀតនៅខាងក្រៅពីកិច្ចប្រជុំ និងព្រឹត្តិកាណ៍សង្គមដទៃទៀតដែលមិនទាក់ទងនឹងកសិកម្ម។

៨. កសិករភាគច្រើនប្រហែលជាមិនយល់អំពីថ្លៃចំណាយនៃសកម្មភាពនីមួយៗទេ ប៉ុន្តែពួកគេពិតជាយល់អំពីជំហានៗក្នុងការបង្កើតហើយអាចបង្កើតតារាងរៀបរាប់ពីសកម្មភាពទាំងអស់នោះបានយ៉ាងងាយស្រួល។ ផ្តោតលើតារាងមួយនោះ ហើយបន្ទាប់មកអ្នកសម្របសម្រួលទីផ្សារ ឬបុគ្គលិកផ្សព្វផ្សាយអាចចង្អុលបង្ហាញពីការចំនាយផ្សេងៗបាន។ កសិករនឹងអាចធ្វើការកំនត់តំលៃលក់សំរាប់ដំណាំនីមួយៗបាន ហើយនឹងអាចដឹងថាវាខុសគ្នាយ៉ាងណាទៅតាមរដូវកាលនីមួយ។

## ប្រអប់០២ ៖ ការគិតគូរអំពីយេនឌ័រប្រកបដោយបរិយាបន្ន

ដើម្បីលើកស្ទួយការយល់ដឹងនៃបញ្ហាប្រឈមរបស់កសិករជាស្ត្រី គម្រោងឈេនបានរៀបចំដៃគូសន្ទនាលក្ខណៈគ្រួសារ និងសហគមន៍ (រួមគ្នាសម្របសម្រួលដោយមន្ទីរកិច្ចការនារី) រវាងបុរសនិងស្ត្រី ដើម្បីពិភាក្សាអំពីការបែងចែកពេលវេលា ការធ្វើសេចក្តីសម្រេចិត្ត និងទំនាក់ទំនងទីផ្សារ។ នៅក្នុងកិច្ចប្រជុំអាជីវកម្មទៅអាជីវកម្ម យើងបានជំរុញការពិភាក្សាអំពីយេនឌ័រប្រកបដោយបរិយាបន្ន ដោយសួរអ្នកទិញ អាជីវករ និងអ្នកលក់ធាតុចូលកសិកម្មថាតើពួកគេបានគិតថាមានភាពខុសគ្នារវាងអតិថិជនជាស្ត្រី និងជាបុរសដែរឬទេ និងថាតើពួកគេបានយល់ដឹងអំពីយុទ្ធសាស្ត្រផ្សេងៗអ្វីខ្លះដែលចាំបាច់ក្នុងការគាំទ្រដល់កសិករជាស្ត្រី។

**តាមរយៈការពិភាក្សាទាំងនេះ និងតាមរយៈអន្តរការរបស់គម្រោងឈេនជាមួយកសិករជាស្ត្រីរាប់រយនាក់ យើងបានរកឃើញបញ្ហាមួយចំនួនដែលពួកគេប្រឈម៖**





**១.** ស្ត្រីមានតួនាទីជាច្រើននៅផ្ទះ រួមមាន ដាំដុះបន្លែ មើលថែកូន និងធ្វើការងារក្នុងផ្ទះជាដើម។ ជាធម្មតាពួកគេធ្វើការច្រើនម៉ោងជាងបុរស ដូច្នេះពេលវេលា និងការប្រមូលផ្តុំរបស់ពួកគេនៅមានកម្រិត។ ការងារទាំងនោះបានរារាំងពួកគេមិនបានចូលរួមក្នុងកិច្ចប្រជុំក្រុម និងការបង្កើតចំណងទំនាក់ទំនងអាជីវកម្មដែលធ្វើអោយពួកគេទទួលបានព័ត៌មានទីផ្សារតិចតួច។



**២.** ស្ត្រីជាធម្មតាបារម្ភច្រើនអំពីសុវត្ថិភាពរបស់ពួកគេនៅពេលធ្វើដំណើរឆ្ងាយពីផ្ទះ ដែលជាកត្តារារាំងពួកគេពីការចូលរួមក្នុងវគ្គបណ្តុះបណ្តាល កិច្ចប្រជុំក្រុមកសិករ ទិវាបង្ហាញនៅទីវាល និង/ឬ កិច្ចប្រជុំផ្សេងៗជាមួយអាជីវករ និងអ្នកលក់ធាតុចូលកសិកម្ម។



**៣.** ស្ត្រីជាធម្មតាមិនមានប្រវត្តិខ្ចីឥណទាន ដូច្នេះពួកគេមិនត្រូវបានចាត់ទុកជាអតិថិជនអាទិភាពដោយមន្ត្រីឥណទាននៃស្ថាប័នហិរញ្ញវត្ថុនោះទេ។



**៤.** ទោះបីកសិករជាស្ត្រីជាធម្មតាពេញចិត្តនឹងសិទ្ធិក្នុងការសម្រេចចិត្តស្មើនឹងបុរសនៅក្នុងផ្ទះសំបែងក៏ដោយ នេះមិនមែនជាករណីនៅកម្រិតក្រុមនោះទេ។

ភាពខុសគ្នាទាំងនេះ ទាមទារអោយមានយុទ្ធសាស្ត្រផ្តល់សិទ្ធិអំណាចសម្រាប់ស្ត្រី ក្នុងការលើកកម្ពស់ចំណងទំនាក់ទំនងពាណិជ្ជកម្ម។ ឧទាហរណ៍៖ កិច្ចប្រជុំ វគ្គបណ្តុះបណ្តាល និងទិវាបង្ហាញ គួរត្រូវបានរៀបចំឡើងនៅពេលវេលា និងទីតាំងដែលសមរម្យសម្រាប់ស្ត្រីក្នុងការចូលរួម។

នៅក្នុងតំណភ្ជាប់អាជីវកម្មទៅអាជីវកម្ម ស្ត្រីចាប់អារម្មណ៍ជាពិសេសលើធាតុចូលកសិកម្មដែលមិនតម្រូវអោយប្រើកម្លាំងពលកម្មច្រើនពេក និងចាប់អារម្មណ៍លើអ្នកប្រមូលទិញនូវដំណាំទាំងនោះ ព្រមទាំងបច្ចេកវិទ្យាដែលសន្សំកម្លាំង។ ហេតុដូច្នេះហើយ គួរពិភាក្សាអំពីដំណាំ និងបច្ចេកវិទ្យាទាំងនេះក្នុងអំឡុងពេលកិច្ចប្រជុំក្រុមកសិករ និងទិវាបង្ហាញដែលជាការវិនិយោគពេលវេលាមួយដ៏ល្អ។

# ៥.៦ សម្របសម្រួលផែនការផលិតកម្ម

**ការរៀបចំផែនការផលិតកម្មគឺជាដំណើរការដ៏សំខាន់មួយដែលត្រូវពិចារណាមុនពេលអ្នករៀបចំកិច្ចសន្យាទិញលក់ជាមួយអ្នកទិញ ដើម្បីឆ្ពោះទៅរកការរីកចម្រើនផ្នែកផលិតកម្ម និងទីផ្សារផលិតផលប្រកបដោយជោគជ័យ។ ផែនការផលិតកម្មចង្អុលបង្ហាញថានរណានឹងផលិតដំណាំអ្វី ហើយប្រមូលផលបានបរិមាណប៉ុណ្ណានៅក្នុងខែណាមួយជាក់លាក់។ ការរៀបចំផែនការនេះនឹងធានាបានថាកសិករដាំដុះអ្វីដែលទីផ្សារមានតម្រូវការ។**

ផែនការផលិតកម្មចាប់ផ្តើមឡើងដោយការជ្រើសរើសមុខដំណាំត្រឹមត្រូវសម្រាប់ក្រុមកសិករដាំដុះ។ ដើម្បីរៀបចំផែនការអោយមានប្រសិទ្ធភាព អ្នកចាំបាច់ត្រូវដឹងអំពីហានិភ័យ និងឱកាសនានាសម្រាប់ប្រភេទដំណាំនីមួយៗ។ ការកំណត់តម្លៃគឺមានភាពពិបាកណាស់ ដោយសារវាអាចប្រែប្រួលខ្លាំងអាស្រ័យលើការផ្គត់ផ្គង់ (លើស)។ គម្រោងឈេនស្នើអោយកសិករអាចលើកឡើងនូវតម្លៃលក់រំពឹងទុកផ្អែកលើអ្វីដែលកសិករធ្លាប់ដឹងពីបទពិសោធន៍ពីមុនៗ ក្នុងការស្រាវជ្រាវក៏ដូចជាវិភាគទីផ្សារ (សូមមើលផ្នែក 5.1 និង 5.2)។ ជ្រើសរើសមុខដំណាំត្រូវដាំគឺជាការងាយស្រួល ប៉ុន្តែជ្រើសរើសដំណាំដែលត្រឹមត្រូវតាមតម្រូវទីផ្សារនៅក្នុងតម្លៃមួយដែលអាចទទួលយកបានគឺជាការលំបាក។ ដូច្នេះហើយ មុនធ្វើការសម្រេចចិត្តជ្រើសរើសប្រភេទដំណាំ កសិករគួរតែសួរខ្លួនឯងថាតើដំណាំណាដែលសាកសម



នៅក្នុងតំបន់ តើកសិករមានបទពិសោធន៍ដាំវាដែរឬទេ ហើយអ្វីជាហានិភ័យនៅពេលដាំដុះខុសរដូវ។ ជាកត្តាសំខាន់ណាស់ក្នុងអំឡុងពេលធ្វើផែនការផលិតកម្ម អ្នកត្រូវមានព័ត៌មានទីផ្សារដ៏ត្រឹមត្រូវមួយ។ គម្រោងឈេនផ្តល់ដំបូន្មានថា អាជីវករពាក់ព័ន្ធទាំងឡាយដែលក្រុមកសិករមានបំណងចង់ចុះកិច្ចសន្យាទិញលក់ជាមួយ ត្រូវបានអញ្ជើញចូលរួមកកិច្ចប្រជុំរៀបចំផែនការផលិតកម្ម។

## ជំហានក្នុងការបង្កើត និងព្រមព្រៀងលើផែនការផលិតកម្ម៖



១. ធ្វើបញ្ជីមុខដំណាំសំខាន់ៗ និងតម្រូវការទីផ្សារលើដំណាំនោះក្នុង១សប្តាហ៍ (គក/សប្តាហ៍) និង១រដូវកាល។ ក្នុងករណីមានតម្រូវការខុសៗគ្នាក្នុងពេល១ឆ្នាំ បង្កើតក្រាហ្វសាមញ្ញមួយដើម្បីបង្ហាញថាខែ ឬរដូវណាមានតម្រូវការបរិមាណ ខ្ពស់ឬទាប។

២. ធ្វើបញ្ជីក្រុមកសិករផលិត ថាតើម្នាក់ៗមានផ្ទៃដីដាំប៉ុន្មានម៉ែត្រការេ (ម២) សម្រាប់ការដាំពេញ១ឆ្នាំ និងផ្ទៃដីផលិតកម្មទំហំប៉ុន្មានម៉ែត្រការេដែលពួកគេមានសម្រាប់ដាំដុះបន្ទាប់បន្សំ ដោយគិតផលិតកម្មជាសប្តាហ៍។

៣. បង្កើតតារាងដំណាំក្នុង១ត្រីមាស/កន្លះឆ្នាំ ដោយដាក់ជាខែនៅលើអ័ក្សផ្តេក និងឈ្មោះកសិករនៅលើអ័ក្សបញ្ឈរ។ អនុញ្ញាតអោយកសិករនីមួយៗជ្រើសរើសមុខដំណាំដែលពួកគេចង់ដាំ និងអោយពួកគេបង្ហាញនៅលើតារាងរៀបចំផែនការថាតើផ្ទៃដីប៉ុន្មានម៉ែត្រការេដែលពួកគេមានផែនការដាំក្នុង១មុខដំណាំ ហើយដាំក្នុងខែណា។

៤. ធ្វើបញ្ជីទំហំចម្ការផលិតកម្ម (ម២) នៅពេលប្រមូលផលសម្រាប់កសិករម្នាក់ៗក្នុង១សប្តាហ៍ និងគណនាចំនួនគីឡូក្រាមដែលកសិករនីមួយៗអាចប្រមូលផលបាន។ ធ្វើការគណនានូវបរិមាណសរុប និងធ្វើការកែសម្រួលដើម្បីផ្គូផ្គងជាមួយតម្រូវការរបស់អាជីវករ។

## សណ្ដែកគួរ ប្រតិទិនផលិតកម្មជា ម$^{២}$ សម្រាប់ការប្រមូលផល

| កសិករ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ធី | | | | | | | | | | | | |
| វណ្ណនះ | | | | | | | | | | | | |
| លី | | | | | | | | | | | | |
| សុគន្ធា | | | | | | | | | | | | |
| សុជាតា | | | | | | | | | | | | |
| សរុប | | | | | | | | | | | | |

## សណ្ដែកគួរ ប្រតិទិនប្រមូលផល ( គក/ថ្ងៃ )

| កសិករ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ធី | | | | | | | | | | | | |
| វណ្ណនះ | | | | | | | | | | | | |
| លី | | | | | | | | | | | | |
| សុគន្ធា | | | | | | | | | | | | |
| សុជាតា | | | | | | | | | | | | |
| សរុប | | | | | | | | | | | | |

### ប្រអប់០៣៖ វិធីធ្វើអោយប្រសើរឡើងនូវទំនាក់ទំនងទំនុកចិត្តរវាង ក្រុមហ៊ុនប្រមូលទិញ និងក្រុមកសិករផលិត

កិច្ចសន្យាទិញលក់រវាងក្រុមកសិករផលិត និងក្រុមហ៊ុនប្រមូលទិញ អាចត្រូវបានរៀបចំឡើងជាផ្លូវការ និងមិនផ្លូវការ។ កិច្ចសន្យាមានគុណសម្បត្តិជាច្រើន ដូចជាធានាបាននូវទីផ្សារសម្រាប់កសិករ ហើយនិងផលិតផលសម្រាប់អ្នកទិញ ដោយមិនបំពានលើកិច្ចសន្យាដែរ។ ទាំងនេះជាបញ្ហាដែលរឿយៗតែងតែកើតមាន (ការលួចលក់ទៅខាងក្រៅដោយកសិករ ឬអ្នកទិញដែលសន្យាទិញនូវបរិមាណជាក់លាក់ណាមួយ ប៉ុន្តែក្រោយមកមិនគោរពតាមកិច្ចសន្យា) ដូច្នេះកិច្ចសន្យាគួរត្រូវបានបង្កើតដើម្បីបង្កើនទំនាក់ទំនងទំនុកចិត្តរវាងអ្នកទិញ និងក្រុមកសិករផលិត។ ប្រសិនកសិករដាំដុះមុខដំណាំថ្មីមួយ អនុញ្ញាតអោយពួកគេសាកល្បងពីរវដ្តដំណាំ។ បង្កើតកិច្ចព្រមព្រៀងជាក់លាក់លើទំហំតម្រូវការ ហើយក្រុមហ៊ុនគួរតែពិនិត្យថាតើកសិករមានដី ទឹក និងសមត្ថភាពគ្រប់គ្រាន់ក្នុងការផលិតតាមទំហំតម្រូវការដែរឬទេ។ ក្រុមហ៊ុនអាចធ្វើការស្នើសុំការជួយគាំទ្រពីអង្គការក្រៅរដ្ឋាភិបាល ឬរដ្ឋាភិបាលនៅក្នុងទំនាក់ទំនង៤P ឬសម្ព័ន្ធផលិតកម្ម។ ក្រុមហ៊ុនទាំងឡាយគួរមានឆន្ទៈក្នុងការវិនិយោគក្រោមការជួយសម្របសម្រួលរៀបចំធ្វើកុងត្រាដោយបុគ្គលិកពាក់ព័ន្ធនៅមូលដ្ឋាន។ ប្រសិនពួកគេមិនមានឆន្ទៈនោះទេ ឱកាសនៃភាពបរាជ័យគឺខ្ពស់ (ក្រុមហ៊ុនគួរចុះពិនិត្យមើលដីចម្ការរបស់កសិករ ផ្ដល់ដំបូន្មានផលិតកម្ម ដោយការចុះពិនិត្យមើលផ្ទាល់ និងមានវត្តមាននៅដីចម្ការដាំដុះទាំងនោះ ជាការកសាងទំនុកចិត្ត និងកាត់បន្ថយការលួចលក់ទៅខាងក្រៅ)។ កិច្ចព្រមព្រៀងលើតម្លៃមុនពេលប្រមូលផលអាចត្រូវបានលើកឡើងពិភាក្សា ប៉ុន្តែអ្វីដែលប្រសើរបំផុតគឺការព្រមព្រៀងលើតម្លៃអប្បបរមា និងទំហំបរិមាណតម្រូវការបន្ទាប់មកចរចាតម្លៃទីផ្សារទូទៅ។ ឧទាហរណ៍៖ ឧបមាថាតម្លៃទីផ្សារ + ១០%។ ក្រុមហ៊ុនប្រមូលទិញ និងក្រុមកសិករទាំងឡាយ គួរចាត់ទុកគ្នាទៅវិញទៅមកជាដៃគូ ដើម្បីទំនាក់ទំនងអាជីវកម្មជាមួយគ្នាបានយូរអង្វែង ដោយមិនចាត់ទុកគ្នាគ្រាន់តែជាអ្នកលក់ និងអ្នកទិញធម្មតានោះទេ។ ពួកគេគួរតែសកម្មក្នុងការប្រាស្រ័យទាក់ទងព័ត៌មានទីផ្សារ មានការរៀបចំប្រជុំទៀងទាត់ដើម្បីពិភាក្សាលើដំណើរការផលិតកម្ម និងទំនាក់ទំនងគ្នាតាមទូរស័ព្ទជាប្រចាំ។ ភាពខុសគ្នាលើស្តង់ដារគុណភាពគឺជាបញ្ហាមួយផ្សេងទៀតដែលត្រូវបានលើកឡើងជាញឹកញាប់។ អ្នកទិញគួរប្រាកដលើស្តង់ដារគុណភាពបែបណាដែលខ្លួនមានតម្រូវការ និងគួរមានគំរូជាក់លាក់ដើម្បីបង្ហាញទៅកសិករ។ ប្រសិនបើមានការផ្គត់ផ្គង់ផលិតផលលើសកម្រិតនៅលើទីផ្សារ អ្នកទិញមានទំនោរបោះបង់ផលិតផលជាច្រើនដែលមានគុណភាពទាប។ ផ្ទុយទៅវិញ ប្រសិនបើមានការផ្គត់ផ្គង់ផលិតផលទាបជាងកម្រិតតម្រូវការ នោះតម្លៃគឺបានខ្ពស់ ហើយកសិករមានទំនោរលក់ផលិតផលទៅអោយអ្នកទិញល្អបំផុតទី១ ដែលអាចទូទាត់ប្រាក់ភ្លាមៗ។ យ៉ាងណាមិញ ប្រសិនបើនៅពេលកិច្ចសន្យា បានផ្ដល់ប្រាក់ជំពាក់ជាមុនសម្រាប់ទិញធាតុចូលដើម្បីដាំដុះនោះអាចបង្ករអោយមានបញ្ហាមួយចំនួន។

# ៥.៧ សម្របសម្រួលកិច្ចព្រមព្រៀង



នៅពេលក្រុមកសិករបានរៀបចំផែនការអាជីវកម្ម និងផលិតកម្មរួចរាល់ហើយ ពួកគេនឹងត្រូវការជំនួយក្នុងការផ្សារភ្ជាប់ជាមួយអាជីវកម្មដែលពាក់ព័ន្ធផ្សេងៗ ដែលជាធាតុសំខាន់មួយនៅក្នុងវិធីសាស្ត្រអាជីវកម្មទៅអាជីវកម្ម។ កិច្ចព្រមព្រៀងអាចជាផ្លូវការ (លាយល័ក្ខអក្សរ) ឬមិនផ្លូវការ (ជាការចរចាពាក្យសំដី)។ ទោះបីផ្លូវការ ឬមិនផ្លូវការ វាមានសារៈសំខាន់ដែលអ្នកចូលរួមទាំងអស់យល់អំពីគោលគំនិតនៃកិច្ចព្រមព្រៀងរួមមាន តួនាទី ទំនួលខុសត្រូវ និងការតាំងចិត្ត ព្រមទាំងការគោរពតាម។ កិច្ចព្រមព្រៀងគួរមានជំហរ ឈ្នះ ឈ្នះ ដោយផ្តល់ប្រយោជន៍ដល់ភាគីទាំងអស់ដែលពាក់ព័ន្ធ។

គម្រោងរបស់អ្នកអាចជួយកសាងសមត្ថភាព និងកាត់បន្ថយហានិភ័យសម្រាប់ការចូលរួមនៅក្នុងកិច្ចព្រមព្រៀងទាំងនោះតាមរយៈការដាក់ពង្រាយធនធានតាមលទ្ធភាពរបស់ខ្លួន។ ឧទាហរណ៍៖ អាជីវករដែលចង់ធ្វើការជាមួយកសិករច្រើនប្រហែលដំបូងត្រូវការវិនិយោគលើយាន្តជំនិះដើម្បីបង្កើនសមត្ថភាពដឹកជញ្ជូន។ ជាផ្នែកមួយនៃកិច្ចព្រមព្រៀងរវាងអាជីវករ និងក្រុមកសិករគោលដៅ គម្រោងអាចផ្តល់ការសហវិនិយោគដើម្បីទិញរ៉ឺម៉កឬឡានដឹកសម្រាប់អាជីវករ។

## ខាងក្រោមនេះគឺជាជំហាននីមួយៗដែលគាំទ្រដល់ការបង្កើតកិច្ចព្រមព្រៀង៖

១. វិភាគឱកាសនានា សម្រាប់កិច្ចព្រមព្រៀងដែលកើតចេញពីកិច្ចប្រជុំក្រុមកសិករ។ ជាងនេះទៅទៀត អ្នកអាចជួបជាមួយតួអង្គទីផ្សារដែលពាក់ព័ន្ធ ដូចជា៖ អាជីវករ អ្នកលក់ធាតុចូលកសិកម្ម អ្នកប្រមូលទិញធំៗ និងអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុ ដើម្បីបង្កើតឱកាសផ្សេងៗ។

២. អំឡុងពេលកិច្ចប្រជុំជាមួយតួអង្គទីផ្សារ ស្វែងយល់ពីបំណងប្រាថ្នារបស់ពួកគេសម្រាប់ពេលអនាគត (តើពួកគេចង់ពង្រីកអាជីវកម្មរបស់ខ្លួនយ៉ាងដូចម្តេច?) និងឧបសគ្គផ្សេងៗ (អ្វីដែលរារាំងពួកគេមិនអោយសម្រេចបាននូវការលូតលាស់នៃអាជីវកម្ម?)។ បំណងប្រាថ្នា និងឧបសគ្គទាំងនេះនឹងចង្អុលបង្ហាញផ្លូវទៅរកកិច្ចព្រមព្រៀងឈ្នះ ឈ្នះ ជាមួយតួអង្គទីផ្សារ។ ឧទាហរណ៍៖ ប្រសិនបើអ្នកលក់ធាតុចូលកសិកម្មចង់បង្កើនការលក់ និងក្រុមកសិករចង់ចាប់ផ្តើមទិញគ្រាប់ពូជដែលមានគុណភាពខ្ពស់ជាកញ្ចប់រួមគ្នា ប្រហែលកិច្ចព្រមព្រៀងអាចត្រូវបានសម្របសម្រួល ដែលអ្នកលក់រាយអាចផ្តល់នូវការបញ្ចុះតម្លៃពិសេសទៅកាន់កសិករជាថ្នូរសម្រាប់ការបញ្ជាទិញជាកញ្ចប់ធំនេះ។

៣. មុនពេលឈានទៅមុខបន្តនៃកិច្ចព្រមព្រៀង រៀបចំឯកសារបំពេញកិច្ចងាយៗជាមួយតួអង្គទីផ្សារដែលពាក់ព័ន្ធ។ តើអាជីវកម្មនីមួយៗមានប្រវត្តិយ៉ាងដូចម្តេច? តើអាជីវកម្មនោះមានកេរ្តិ៍ឈ្មោះយ៉ាងណាក្នុងទីផ្សារ?

៤. ចាប់ផ្តើមសម្របសម្រួលកិច្ចព្រមព្រៀងរវាងតួអង្គទីផ្សារដែលពាក់ព័ន្ធ។ នេះអាចហៅថាជាដំណើរការពហុជំហាន។ អ្នកប្រហែលអាចចាប់ផ្តើមរៀបចំកិច្ចប្រជុំមិនផ្លូវការ “ការស្គាល់គ្នា” រវាងអាជីវករម្នាក់ជាមួយនឹងក្រុមកសិករមួយ ឬច្រើន ហើយបន្ទាប់មកបន្តដំណើរការប្រជុំពិភាក្សាជាច្រើនទៀត ដោយធ្វើការស្វែងយល់លម្អិតពីកិច្ចព្រមព្រៀង។ ទោះបីកិច្ចព្រមព្រៀងមានលក្ខណៈមិនផ្លូវការក៏ដោយ កត់ត្រាព័ត៌មានលម្អិតទាំងអស់ និងពិនិត្យមើលជាមួយភាគីនីមួយៗដើម្បីធានាបាននូវការយល់ដឹង និងការប្តេជ្ញាចិត្តច្បាស់លាស់។

៥. នៅពេលកិច្ចព្រមព្រៀងត្រូវបានបង្កើតហើយ សូមរក្សានូវការចូលរួម ពីព្រោះជៀសមិនរួចនឹងមានបញ្ហាមួយចំនួនដែលត្រូវដោះស្រាយ។

៦. ប្រសិនបើគម្រោងបានលៃលកធនធានហិរញ្ញវត្ថុ ឬធនធានមនុស្សជាក់លាក់ ក្រុមការងារគួរធានាថាធនធានទាំងនោះត្រូវបានផ្តល់ការងារដូចការរំពឹងទុក និងធានាថារាល់ព័ត៌មានសំខាន់ណាចាំបាច់សម្រាប់ធ្វើរបាយការណ៍គឺត្រូវបានប្រមូលពីភាគីទាំងឡាយដែលពាក់ព័ន្ធនៅក្នុងកិច្ចព្រមព្រៀង។





# ព័ត៌មានជំនួយ

១. ការបង្កើតកិច្ចព្រមព្រៀងតែងតែជាជំនាញថ្មីមួយសម្រាប់បុគ្គលិកគម្រោង ដូច្នេះវាជាការសំខាន់ក្នុងផ្តល់ការបណ្តុះបណ្តាលក្នុងថ្នាក់ ក៏ដូចជាការបង្ហាត់បង្ហាញតាមរយៈការអនុវត្តការងារជាក់ស្តែង នៅពេលពួកគេចាប់ផ្តើមវិភាគ សម្របសម្រួល និងដោះស្រាយបញ្ហានៃកិច្ចព្រមព្រៀង។

២. ដើម្បីជៀសវាងការប៉ះទង្គិចគ្នារវាងភាគីទាំងឡាយនៃកិច្ចព្រមព្រៀង អ្នកគួរព្យាយាមអោយមានការចូលរួមពីប្រធានភូមិ និង/ឬមន្ត្រីរដ្ឋាភិបាលថ្នាក់ក្រោមជាតិដូចជាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាដើម។ ប្រសិនបើពួកគេបានស្គាល់ភាគីពាក់ព័ន្ធទាំងនោះ យល់អំពីកិច្ចព្រមព្រៀង និងឯកភាពក្នុងការគាំទ្រ ពួកគេអាចជួយគ្រប់គ្រង និងបញ្ជៀសបញ្ហាទាំងនោះនាពេលអនាគត។

៣. នៅពេលសម្របសម្រួលកិច្ចព្រមព្រៀង ពិភាក្សានូវហានិភ័យ ការកាត់បន្ថយហានិភ័យជាមួយគ្រប់ភាគីទាំងអស់ ជាពិសេសជាមួយកសិករដែលមានចំណូលទាប។



# ៥.៨ តាមដាន



ការងារសម្របសម្រួលអាជីវកម្មទៅអាជីវកម្មមិនមែនបញ្ចប់ត្រឹមការសម្របសម្រួលកិច្ចព្រមព្រៀងនោះទេ។ ដើម្បីធានាថាកសិករអនុវត្តតាមអ្វីដែលពួកគេបានរៀបចំ និងយល់ព្រម អ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្មត្រូវតែបន្តតាមដានទាំងនៅពេលបញ្ហាកំពុងកើតឡើង ឬដោយធ្វើកាលវិភាគណាត់ជួបភាគីពាក់ព័ន្ធទាំងអស់នៅចន្លោះពេលណាមួយទៀងទាត់ ដូចជា មួយត្រីមាសម្តងជាដើម។

**នៅក្នុងកិច្ចប្រជុំតាមដានទាំងនេះ អ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្មអាចលើកឡើងនូវបញ្ហាផ្សេងៗដែលពួកគេបានកត់សម្គាល់ ឬត្រូវបានរាយការណ៍។ អ្នកចូលរួមអាចស្តាប់ទៅនឹងបញ្ហាទាំងឡាយ និងចែករំលែកគំនិតយោបល់ដើម្បីដោះស្រាយបញ្ហាទាំងនោះជាមួយគ្នា។**

## គម្រោងឈេនផ្តល់យោបល់អោយប្រើប្រាស់វិធីសាស្ត្រខាងក្រោម៖

- ប្រមូលព័ត៌មានទីផ្សារយ៉ាងហោចណាស់មួយឆ្នាំម្តង ប៉ុន្តែបើប្រមូលតាមរដូវនៃការដាំដុះកាន់តែប្រសើរ។ នៅពេលវិភាគព័ត៌មាន រកមើលចំណុចផ្លាស់ប្តូរតាមពេលវេលា ដើម្បីកំណត់និន្នាការដែលអ្នកអាចពិភាក្សាជាមួយកសិករ ដៃគូ និងតួអង្គទីផ្សារពាក់ព័ន្ធផ្សេងៗ។

- ជួបជាមួយក្រុមកសិករជាទៀងទាត់ ដើម្បីផ្តល់ការគាំទ្របន្ត ផ្តល់ឱកាសអោយពួកគេដើម្បីជួយគាំទ្រគ្នាទៅវិញទៅមក និងបង្កើតវេទិកានៅកន្លែងណាដែលតួអង្គទីផ្សារដទៃទៀតអាចអញ្ជើញចូលរួមសម្រាប់ការពិភាក្សា ផ្លាស់ប្តូរគំនិតយោបល់ បណ្តុះបណ្តាល រៀបចំផែនការ និងប្រហែលអាចបង្កើតកិច្ចព្រមព្រៀងបាន។

- នៅចន្លោះកិច្ចប្រជុំក្រុមកសិករ សួរបញ្ជាក់ជាមួយអ្នកដឹកនាំក្រុម និងកសិករម្នាក់ៗថាតើនរណាប្រហែលត្រូវការ ការគាំទ្របន្ថែម។

- ធ្វើការតាមដានទៀងទាត់ជាមួយតួអង្គទីផ្សារដទៃទៀត (អ្នកលក់ធាតុចូលកសិកម្ម អាជីវករក្នុងតំបន់ អ្នកផ្តល់សេវាកម្មបច្ចេកទេស និងមន្ត្រីរដ្ឋាភិបាលនានា) ដែលនេះនឹងជួយដល់ក្រុមការងារបានយល់ដឹងពីតម្រូវការ និងឱកាសនៅក្នុងទីផ្សារ និងរបៀបដែលទីផ្សារមានការផ្លាស់ប្តូរពីពេលមួយទៅពេលមួយ។

- ទោះបីជាការកសាងទំនាក់ទំនង និងការគាំទ្រពិតជាមានតម្លៃ ព្រមទាំងនាំមកនូវឱកាសជាច្រើនយ៉ាងណាក៏ដោយ គួរចងចាំថាក្រុមការងារគម្រោងគឺជាកត្តាជំរុញបណ្តោះអាសន្នប៉ុណ្ណោះ។ ពួកគេគឺជាអ្នកសម្របសម្រួលអោយមានការផ្លាស់ប្តូរជាវិជ្ជមាន ប៉ុន្តែពួកគេមិនត្រូវបង្កើតភាពពឹងពាក់អាស្រ័យនៃតួអង្គទីផ្សារដែលពួកគេកំពុងគាំទ្រនោះទេ។



# ព័ត៌មានជំនួយ

១. នៅពេលកសិករសាកល្បងដំណាំថ្មី ពូជ ធាតុចូល វិធីសាស្រ្ត និងបច្ចេកទេសថ្មីៗ ពួកគេទំនងនឹងត្រូវការដំបូន្មានលើកិច្ចព្រមព្រៀងដ៏ល្អសមស្របមួយ។ ខណៈដែលមានការអនុវត្តន៍ល្អ និងការផ្តល់ដំបូន្មានកាន់តែច្រើន កាន់តែប្រសើរតាមរយៈតួអង្គទីផ្សារ បុគ្គលិកប្រហែលចាំបាច់ត្រូវបំពេញព័ត៌មានដែលខ្វះចន្លោះបន្ថែមអំឡុងពេលទីផ្សារកំពុងមានការវិវត្តន៍។ ពួកគេនឹងត្រូវបន្តការបណ្តុះបណ្តាលដើម្បីផ្តល់ការតាមដានបច្ចេកទេសដល់កសិករ។

២. ខណៈពេលកសិករ និងតួអង្គទីផ្សារដទៃទៀតស្វែងរកការពង្រីកអាជីវកម្មរបស់ពួកគេ ពួកគេនឹងត្រូវការចាំបាច់ផងដែរនូវការគាំទ្រផ្នែកហិរញ្ញវត្ថុ។ ការឈានទៅរកឥណទានគួរត្រូវបានសម្របសម្រួលប្រកបដោយទំនួលខុសត្រូវ យើងមិនចង់អោយកសិករទទួលបំណុលកាន់តែច្រើនជាងអ្វីដែលពួកគេអាចគ្រប់គ្រងបាននោះទេ ប៉ុន្តែយើងចង់បើកផ្លូវទូលាយដើម្បីការចាប់យកឱកាសវិនិយោគ។ ការវិភាគសេដ្ឋកិច្ចដំណាំសមរម្យ (ការវិភាគចំណាយ/ចំណូល) សម្រាប់វដ្តដំណាំខុសៗគ្នា និងការសម្រេចចិត្តវិនិយោគ គួរត្រូវបានពិភាក្សាជាមួយកសិករ និងស្ថាប័នហិរញ្ញវត្ថុ។

៣. ការកត់ត្រាអោយបានត្រឹមត្រូវតែងតែជាការលំបាក និងវាគួរតែជាអាទិភាពទាបរបស់កសិករ។ ទម្រង់តាមដានដែលអាចជួយបានមួយគឺ ការកត់ត្រាគាំទ្រដោយបុគ្គលិកទៅលើថ្លៃដើមធាតុចូល ទិន្នផល តម្លៃ គុណភាព និងចំណូល ដែលការកត់ត្រាទាំងនេះអាចត្រូវបានប្រើប្រាស់ដើម្បីជំរុញផែនការផលិតកម្ម និងអាជីវកម្មនាពេលអនាគត។



# ៦. សន្និដ្ឋាន



ខណៈពេលគោលការណ៍ និងវិធីសាស្ត្រទាំងឡាយដែលបានលើកឡើងអាចអនុវត្តបានទៅកាន់គំនិតផ្តួចផ្តើមការអភិវឌ្ឍផ្សេងៗជាច្រើន គម្រោងឈេនសង្ឃឹមយ៉ាងមុតមាំថានឹងអាចជំរុញអង្គការក្រៅរដ្ឋាភិបាល និងទីភ្នាក់ងាររដ្ឋាភិបាលថ្នាក់ក្រោមជាតិក្នុងប្រទេសកម្ពុជា ព្រមទាំងស្ថាប័នធំៗផ្សេងៗទៀត អោយទទួលយកគម្រោងក្នុងការអភិវឌ្ឍវិស័យកសិកម្ម ដែលអនុវត្តន៍តាមគំរូការអភិវឌ្ឍប្រព័ន្ធទីផ្សារ (MSD) ដែលបានផ្តល់នូវលទ្ធផលដ៏មានតម្លៃសម្រាប់គម្រោងឈេន។

សម្រាប់ព័ត៌មានជាច្រើនលើដំណាក់កាលនីមួយៗរបស់ឈេន រួមមានឯកសារណែនាំ (ជាភាសាខ្មែរ) ទៅលើបច្ចេកវិទ្យាជាក់លាក់ និងបច្ចេកទេសសាកវប្បកម្ម សូមចូលមើលគេហទំព័រ **https://elibrary.maff.gov.kh.**

ឧបសម្ព័ន្ធនៅក្នុងទំព័របន្តបន្ទាប់ផ្តល់នូវគំរូសម្ភារៈជំនួយជាច្រើនដែលត្រូវបានអភិវឌ្ឍន៍ដោយឈេន សម្រាប់សកម្មភាពផ្សារភ្ជាប់អាជីវកម្មទៅអាជីវកម្ម រួមបញ្ចូលបញ្ជីសំណួរសង្កេតទីផ្សារ និងគំរូសម្រាប់ធ្វើផែនការផលិតកម្ម និងអាជីវកម្ម។ ច្បាប់ចម្លងឌីជីថលនៃឯកសារទាំងនេះអាចទាញយកបានពី **https://elibrary.maff.gov.kh.**

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ១

## វិធីសាស្ត្រសម្រាប់ការស្ទង់មតិអាជីវករ

### ១. កំណត់ទីផ្សារគោលដៅ

ទីផ្សារគោលដៅគឺជាទីផ្សារលក់រាយសម្រាប់អ្នកប្រើប្រាស់ចុងក្រោយដែលសមាជិកក្រុមកសិករតែងតែលក់ផលិតផលរបស់ពួកគេដោយផ្ទាល់ ឬដោយប្រយោល។ ជាធម្មតាការលក់ផលិតផលគឺស្ថិតនៅនឹងចំការរបស់ពួកគេ និង/ឬនៅជិតទីប្រជុំជន។ ទីផ្សារដទៃទៀតណាមួយដែលកសិករប្រហែលមានសក្តានុពលលក់ផលិតផលរបស់ពួកគេ អាចជាគោលដៅផងដែរនៅក្នុងការស្ទង់មតិ។ ទិន្នន័យបន្ទាប់ (ឧទាហរណ៍៖ ព័ត៌មានដែលចងក្រងដោយក្រសួងពាណិជ្ជកម្ម ការិយាល័យស្រុក ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) អាចផ្តល់ការប៉ាន់ប្រមាណនៃចំនួនអាជីវករនៅក្នុងតំបន់ជាក់លាក់ណាមួយ។

### ២. កំណត់ និងជ្រើសរើសសំណាក

ការស្ទង់មតិលើអាជីវករនីមួយៗនៅក្នុងទីផ្សារគោលដៅ គឺជាការប្រឹងប្រែងអស់ពីកាយ និងចិត្ត ដូច្នេះអ្នកគួរតែសម្ភាសន៍តែអាជីវករគំរូបានហើយ។ ការជ្រើសរើសអាជីវករគំរូ គួររាប់បញ្ចូលទាំងអាជីវករធំ និងតូចៗ ចល័ត ឬមិនចល័ត ជាអ្នកមានកិច្ចព្រមព្រៀងក្នុងការលក់ដុំ និងលក់រាយ ព្រមទាំងអាជីវករដែលមកពីទីតាំងផ្សេងៗគ្នាក្នុងស្រុក។ តើមានអាជីវករចំនួនប៉ុន្មាននាក់ដែលអាចចូលរួមជាសំណាកគ្រប់គ្រាន់? ដែលនោះនឹងអាស្រ័យលើទំហំសរុបនៃទីផ្សារទាំងអស់ដែលអ្នកមានផែនការស្ទង់មតិ។ សូមមើលឧបសម្ព័ន្ធ០២ សម្រាប់ការណែនាំពីរបៀបកំណត់ទំហំសំណាកដែលត្រឹមត្រូវ។

### ៣. កំណត់ និងជ្រើសរើសគំរូ

កត់ត្រាព័ត៌មានចេញពីគំរូអាជីវកររបស់អ្នកនៃបញ្ជីសំណួរស្ទង់មតិទីផ្សារ/ ឧបករណ៍សម្រាប់សម្ភាសន៍អាជីវករ (សូមមើលឧទាហរណ៍ក្នុង **ឧបសម្ព័ន្ធ០៣**)។

### ៤. កំណត់ និងជ្រើសរើសគំរូ

នៅពេលអ្នកបានបញ្ចប់ការស្ទង់មតិលើគំរូអាជីវករទាំងអស់រួចរាល់ហើយ អ្នកអាចបញ្ចូលទិន្នន័យនៅក្នុងតារាងកិច្ចការដោយប្រើប្រាស់តារាង Excel ឬ តារាង Google។ ប្រសិនបើការប្រមូលទិន្នន័យត្រូវបានធ្វើឡើងដោយប្រើប្រាស់ apps នោះនឹងមិនសូវជាចាំបាច់ទេ ដោយសារកម្មវិធីនឹងបកស្រាយទិន្នន័យដោយស្វ័យប្រវត្តិ។ កម្មវិធីស្ទង់មតិដ៏ពេញនិយមពីរដែលដំណើរការនៅលើទូរស័ព្ទ និងនៅលើ Tablet គឺ KoBoToolbox *(https://www.kobotoolbox.org/)* និង Google Forms *(https://www.google.com/forms/about/)*។ នៅពេលទិន្នន័យត្រូវបានរៀបចំរួចរាល់ហើយ គឺអាចត្រូវបានវិភាគ និងបកស្រាយជាទម្រង់មើលឃើញដោយប្រើប្រាស់គំនូសតាង និង ក្រាហ្វ។

# ឧបសម្ព័ន្ធ២

## ការកំណត់ទំហំគំរូសម្រាប់ការស្ទង់មតិអាជីវករ

ទំហំសំណាកស្ទង់មតិទីផ្សារអាចត្រូវបានកំណត់ដោយប្រើប្រាស់ទម្រង់ Krejcie and Morgan formula ដែលជាការប៉ាន់ស្មានមួយនៃរូបមន្តកំណត់ទំហំសំណាកដែលគេទទួលស្គាល់។ អ្នកអាចរកតម្លៃត្រឹមត្រូវដោយប្រើម៉ាស៊ីនគណនាទំហំសំណាកតាមអ៊ីនធឺណិតដូចជា *https://www.calculator.net/sample-size-calculator.html* ។

**សម្រាប់គម្រោងឈេន យើងប្រើប្រាស់តម្លៃដូចខាងក្រោម៖**




ចំនួនប៉ាន់ស្មានសរុបនៃអាជីវករបន្លែនៅក្នុងបណ្តាខេត្តទាំង៤៖ ៣២៩
កម្រិតទំនុកចិត្ត៖ ៩០%
កម្រិតលម្អៀង៖ ៥%

នៅពេលទំហំសំណាកត្រូវបានកំណត់ត្រឹមត្រូវហើយ យើងចែកវាជាសមមាត្រក្នុងចំណោមទីផ្សារគោលដៅទាំងអស់ដែលយើងបានកំណត់ផែនការស្ទង់មតិ។ ឧទាហរណ៍៖ ផ្សារសំរោងក្នុងខេត្តឧត្តរមានជ័យមានអាជីវករចំនួន១៣នាក់ ស្មើនឹង៤% នៃចំនួនសរុប៣២៩។ ហេតុដូច្នេះហើយ យើងបានរៀបចំសម្ភាសន៍អាជីវករចំនួន៦នាក់នៅក្នុងផ្សារនោះស្មើនឹង៤% នៃទំហំសំណាកដែលចង់បាននៃ ១៥០។

ប្រសិនបើសំណាកដែលបានគណនាសម្រាប់ផ្សារនីមួយៗគឺច្រើនជាង១៥ ត្រូវកាត់ត្រឹមចំនួន១៥ដើម្បីក្រុមអាចគ្រប់គ្រងបាន។ ប្រសិនបើសំណាកដែលបានគណនាគឺតិចជាង៥ នោះត្រូវរាប់ដល់១៥ដើម្បីបង្កើនសុក្រិតភាព។ ជាលទ្ធផលនៃការកែតម្រូវទាំងនេះ ទំហំសំណាកឡើងដល់១៥៨។

| កសិករ | ឈ្មោះផ្សារ | ចំនួនអាជីវករ | %នៃចំនួនអាជីវករ សរុប | សំណាកដែលបានគណនា | សំណាកដែលបានកែតម្រូវ |
|---|---|---|---|---|---|
| ឧត្តរមានជ័យ | សំរោង | ១៣ | ៤% | ៦ | ៦ |
| ឧត្តរមានជ័យ | អន្លង់វែង | ១៣ | ៤% | ៦ | ៦ |
| ឧត្តរមានជ័យ | អូរស្មាច់ | ៥ | ១,៥% | ២ | ៥ |
| ឧត្តរមានជ័យ | បន្ទាយអំពិល | ៦ | ២% | ៣ | ៥ |
| ឧត្តរមានជ័យ | ត្រពាំងប្រាសាទ | ៩ | ៣% | ៤ | ៥ |
| ព្រះវិហារ | ឆែប | ១១ | ៣% | ៥ | ៥ |
| ព្រះវិហារ | ស្រយ៉ង់ | ១០ | ៣% | ៥ | ៥ |
| ព្រះវិហារ | គូលែន | ៦ | ២% | ៣ | ៥ |
| ព្រះវិហារ | ជ័យសែន | ៦ | ២% | ៣ | ៥ |
| ព្រះវិហារ | កំពង់ប្រណាក | ៣០ | ៩% | ១៤ | ១៤ |
| ព្រះវិហារ | រវៀង | ២២ | ៧% | ១០ | ១០ |
| ស្ទឹងត្រែង | អូរឫស្សី | ១៩ | ៦% | ៩ | ៩ |
| ស្ទឹងត្រែង | សាមគ្គី | ៣៦ | ១១% | ១៦ | ១៥ |
| ក្រចេះ | សាមគ្គី | ៣៥ | ១១% | ១៦ | ១៥ |
| ក្រចេះ | ឆ្លូង | ២៨ | ៨,៥% | ១៣ | ១៣ |
| ក្រចេះ | ព្រះប្រសប់ | ១០ | ៣% | ៥ | ៥ |
| ក្រចេះ | ផែលើ | ៣៨ | ១១,៥% | ១៧ | ១៥ |
| ក្រចេះ | សណ្តាន់ | ១៩ | ៦% | ៩ | ៩ |
| ក្រចេះ | សំបូរ | ១៣ | ៤% | ៦ | ៦ |
| | | ៣២៩ | ១០០% | ១៥២ | ១៥៨ |

# ឧបសម្ព័ន្ធ៣

## បញ្ជីសំណួរស្ទង់មតិទីផ្សារ/ ឧបករណ៍សម្ភាសន៍អាជីវករ

បំពេញបញ្ជីសំណួរ១នៅពេលសម្ភាសន៍ម្តង និងក្នុងពេលម្តងសម្ភាសន៍តែអាជីវករម្នាក់។

**ឧបករណ៍នេះមាន៣ផ្នែក៖**

**១.** ព័ត៌មានទូទៅ

**២.** ព័ត៌មានអំពីការអនុវត្តរបស់អាជីវករ

**៣.** ព័ត៌មានតម្រូវការបន្លែ (ទីផ្សារ)

ផ្នែកព័ត៌មានទូទៅគឺសំដៅចាប់យកទិដ្ឋភាពទូទៅអំពីអាជីវករ។ អាជីវករមួយចំនួនគឺជាបណ្តាល័យ ដែលពួកគេមានហាង ឬតូបជាក់លាក់នៅផ្សារ ខណៈពេលអាជីវករដទៃទៀតលក់ចល័ត ហើយពួកគេប្រហែលជាមានរទេះ ឬចាក់ផលិតផលលក់នៅលើដី ដូច្នេះពួកគេអាចផ្លាស់ប្តូរទីតាំងនៅក្នុងផ្សារ ឬចល័តទៅកន្លែងផ្សេងៗទៀត។

សម្រាប់ការស្ទង់មតិលើការអនុវត្តន៍របស់អាជីវករ ឧបករណ៍ត្រូវបានកំណត់ជាពហុជម្រើស (ជ្រើសរើសចម្លើយ១ឬច្រើន)។ ក្នុងករណីខ្លះ អ្នកសម្ភាសន៍ត្រូវតែស្នើសុំព័ត៌មានបន្ថែម (ឧទាហរណ៍៖ ពន្យល់ជម្រើសដទៃទៀត)។ នៅជួរ "កំណត់ចំណាំ" អនុញ្ញាតអោយអ្នកសម្ភាសន៍ចាប់យកព័ត៌មានចាំបាច់ដទៃទៀតដែលមិនពាក់ព័ន្ធនឹងសំណួរ។ ឧទាហរណ៍៖ ប្រសិនបើអាជីវករនិយាយថា "អតិថិជនជាច្រើនសួរខ្ញុំអំពីបន្លែក្នុងស្រុកពីព្រោះពួកគេពិតជាចង់បានបន្លែដែលមិនប្រើជាតិគីមី" ការដឹងព័ត៌មានសំខាន់នេះត្រូវចាប់ចូលទៅក្នុងជួរ "កំណត់ចំណាំ"។

---

ផ្នែកតម្រូវការបន្លែមានតារាងពីរ។ សូមអនុវត្តនូវការណែនាំខាងក្រោម៖

| | |
|---|---|
| **សំណួរ (c)** | ប្រសិនអាជីវករឆ្លើយ 'បាទ/ចាស' បន្តទៅសំណួរ (d) ដល់ (s) សម្រាប់បន្លែនោះ។ ប្រសិនអាជីវករឆ្លើយ 'ទេ' រំលងទៅបន្លែបន្ទាប់។ |
| **សំណួរ (d) – (h)** | ទាំងនេះជាសំណួរដើមគ្រាសម្រាប់កន្លែងដែលអាជីវកទិញបន្លែរបស់ខ្លួន។ សួរសំណួរសម្រាប់ខែថ្មីៗ។ សម្រាប់លំដាប់លំដោយនេះ៖ (d) = (e) + (f) + (g) + (h). |
| **សំណួរ (i) – (m)** | ទាំងនេះជាសំណួរដើមគ្រាសម្រាប់កន្លែងដែលអាជីវកលក់បន្លែរបស់ខ្លួន។ សួរសំណួរសម្រាប់ខែថ្មីៗ។ សម្រាប់លំដាប់លំដោយនេះ៖ (i) = (j) + (k) + (l) + (m). |
| **សំណួរ (n) – (s)** | ទាំងនេះជាការព្យាករណ៍ ឧទាហរណ៍៖ តម្រូវការប៉ាន់ស្មានរបស់អាជីវករក្នុង១មុខបន្លែក្នុង១ខែ។ |

**វាមានសារៈសំខាន់ណាស់ក្នុងការសួរសំណួរទាំងនេះដោយការប្រុងប្រយ័ត្ន** ដើម្បីព័ត៌មានតម្រូវការអាចប្រៀបធៀបបានចំពោះ អាជីវករ ផ្សារ និងខេត្តទាំងឡាយ។

---

## ផ្នែកទី១៖ ព័ត៌មានទូទៅ

ខេត្ត៖ ____________________ ផ្សារ៖ ____________________

ឈ្មោះអ្នកសម្ភាសន៍៖ ____________________ កាលបរិច្ឆេទសម្ភាសន៍ ៖ ____________________

ឈ្មោះអាជីវករ (អង់គ្លេស)៖ ____________________ ឈ្មោះអាជីវករ (ខ្មែរ)៖ ____________________

លេខទូរស័ព្ទ៖ ____________________ ទំហំអាជីវកម្ម (តូច មធ្យម ឬធំ)៖ ____________________

ចល័ត (M) ឬតូបថេរ (S)៖ ____________________ អ្នកលក់ដុំ (W) ឬអ្នកលក់រាយ (R)៖ ____________________

## ផ្នែកទី២៖ ការអនុវត្តន៍របស់អាជីវករ

| កសិករ | ជម្រើសចម្លើយ | កំណត់ចំណាំ |
|---|---|---|
| ១. ភេទ | គូសរង្វង់មួយ៖<br>ស្រី ប្រុស | |
| ២. ចន្លោះអាយុ | គូសរង្វង់មួយ៖<br>៣០-៤០ ៣០-៤០ ៤០-៥០ | |
| ៣. តើអ្នកមានដឹងអំពីប្រភពបន្លែឬទេ? | គូសរង្វង់មួយ៖<br>a. បាទ/ចាស ខ្ញុំដឹងពីប្រភពបន្លែទាំងអស់<br>b. បាទ/ចាស ខ្ញុំដឹងពីប្រភពបន្លែភាគច្រើន<br>c. បាទ/ចាស ខ្ញុំដឹងពីប្រភពបន្លែខ្លះៗ<br>d. ទេ | |
| ៤. តើអ្នកប្រាប់អតិថិជនរបស់អ្នកអំពីប្រភពបន្លែដែលអ្នកលក់ឬទេ? | គូសរង្វង់ (ចម្លើយអាចលើសពីមួយ)៖<br>a. ប្រាប់តែនៅពេលអតិថិជនសួរ<br>b. ប្រាប់ដោយសកម្មផ្ទាល់មាត់ទៅកាន់អតិថិជន<br>c. ប្រាប់ដោយការញែកបន្លែផ្សេងពីគ្នារវាងបន្លែក្នុងស្រុក និងនាំចូល<br>d. ប្រើសញ្ញាសម្គាល់ដើម្បីបែងចែកបន្លែក្នុងស្រុក<br>e. ផ្សេងទៀត (សូមពន្យល់) | |
| ៥. តើអ្នកប្រាប់អតិថិជនរបស់អ្នកអំពីប្រភពបន្លែដែលអ្នកលក់ឬទេ? | គូសរង្វង់មួយ៖<br>a. អាជីវករមិនដឹងអំពីសារៈប្រយោជន៍<br>b. អាជីវករដឹងអំពីសារៈប្រយោជន៍ប៉ុន្តែប្រាប់ព័ត៌មាននៅពេលតែអតិថិជនសួរនាំ<br>c. អាជីវករដឹងអំពីសារៈប្រយោជន៍ និងសកម្មក្នុងការចែករំលែកព័ត៌មានជាមួយអតិថិជន<br>d. ផ្សេងទៀត (សូមពន្យល់) | |

# ផ្នែកទី៣៖ ព័ត៌មានតម្រូវការបន្លែ

| ឈ្មោះបន្លែ<br>( អង់គ្លេស/ខ្មែរ )<br>(a/b) | (c) តើអ្នកលក់បន្លែទាំងនេះឬ? (Y/N) | **ដើមគ្រោះ<br>តើបន្លែនីមួយៗប៉ុន្មានគកក្នុង១ថ្ងៃ ដែលអាជីវករទិញពីប្រភពផ្សេងៗគ្នា?**<br>(d) = (e) + (f) + (g) + (h)<br>(e) បន្លែប៉ុន្មានគកក្នុង១ថ្ងៃមកពីអាជីវករផ្សេងៗទៀតនៅក្នុងផ្សារនេះ?<br>(f) បន្លែប៉ុន្មានគកក្នុង១ថ្ងៃមកពីអាជីវករផ្សេងៗទៀតនៅក្នុងខេត្តនេះ?<br>(g) បន្លែប៉ុន្មានគកក្នុង១ថ្ងៃមកពីកសិករផ្ទាល់នៅក្នុងខេត្តនេះ?<br>(h) បន្លែប៉ុន្មានគកក្នុង១ថ្ងៃមកពីខាងក្រៅខេត្តនេះ (បន្លែក្នុងស្រុក ឬនាំចូល)? | | | | | **ដើមគ្រោះ<br>តើបន្លែនីមួយៗប៉ុន្មានគកក្នុង១ថ្ងៃ ដែលអាជីវករលក់ទៅកាន់អតិថិជនផ្សេងៗគ្នា?**<br>(i) = (j) + (k) + (l) + (m)<br>(j) បន្លែប៉ុន្មានគកក្នុង១ថ្ងៃលក់ទៅកាន់អតិថិជននៅក្នុងផ្សារនេះ?<br>(k) បន្លែប៉ុន្មានគកក្នុង១ថ្ងៃលក់ទៅកាន់អាជីវកម្មផ្សេងៗ (ភោជនីយដ្ឋាន សណ្ឋាគារ រោងចក្រ ។ល។)?<br>(l) បន្លែប៉ុន្មានគកក្នុង១ថ្ងៃលក់ទៅកាន់អាជីវករផ្សេងៗទៀតនៅក្នុងផ្សារនេះ?<br>(m) បន្លែប៉ុន្មានគកក្នុង១ថ្ងៃលក់ទៅកាន់អាជីវករនៅក្នុងផ្សារ ឬខេត្តផ្សេងទៀត? | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | **(d)**<br>ជាមធ្យម បន្លែប៉ុន្មានគកក្នុង១ថ្ងៃដែលអ្នកទិញ? | (e) | (f) | (g) | (h) | **(i)**<br>ជាមធ្យម បន្លែប៉ុន្មានគកក្នុង១ថ្ងៃដែលអ្នកលក់? | (j) | (k) | (l) | (m) |
| Bitter gourd / ម្រះ | | | | | | | | | | | |
| Bok choy / ស្ពៃតឿ | | | | | | | | | | | |
| Bottle gourd / ឃ្លោក | | | | | | | | | | | |
| Cabbage / ស្ពៃក្តោប | | | | | | | | | | | |
| Cauliflower / ផ្កាខាតណា | | | | | | | | | | | |
| Chili / ម្ទេស | | | | | | | | | | | |
| Chinese kale / ខាតណាដើម | | | | | | | | | | | |
| Chinese mustard / ស្ពៃជើងទា | | | | | | | | | | | |
| Choy sum / ស្ពៃចង្កឹះ | | | | | | | | | | | |
| Cucumber / ត្រសក់ | | | | | | | | | | | |
| Curly mustard / ស្ពៃក្រញាញ់ | | | | | | | | | | | |
| Eggplant / ត្រប់ | | | | | | | | | | | |
| Green mustard / ស្ពៃខៀវ | | | | | | | | | | | |
| Lettuce / សាឡាត | | | | | | | | | | | |
| Long bean / សណ្តែកគួរ | | | | | | | | | | | |
| Luffa gourd /ននោង | | | | | | | | | | | |
| Round eggplant / ត្រប់មូល | | | | | | | | | | | |
| Spring onion / ខ្ទឹមស្លឹក | | | | | | | | | | | |
| Tomato / ប៉េងប៉ោះ | | | | | | | | | | | |
| Water spinach / ត្រកួន | | | | | | | | | | | |
| Wax gourd / ត្រឡាច | | | | | | | | | | | |

| (a)<br>ឈ្មោះបន្លែ (អង់គ្លេស) | (b)<br>ឈ្មោះបន្លែ (ខ្មែរ) | (c)<br>តើអ្នកលក់បន្លែនេះឬ?<br>(បាទ/ទេ) | ការព្យាករណ៍<br>បន្លែដែលចាំបាច់ក្នុង១ថ្ងៃក្នុងខែនីមួយៗ (គក/ថ្ងៃ) | | | | | |
|---|---|---|---|---|---|---|---|---|
| | | | (n)<br>ធ្នូ | (o)<br>មករា | (p)<br>កុម្ភៈ | (q)<br>មីនា | (r)<br>មេសា | (s)<br>ឧសភា |
| Bitter gourd | ម្រះ | | | | | | | |
| Bok choy | ស្ពៃតឿ | | | | | | | |
| Bottle gourd | ឃ្លោក | | | | | | | |
| Cabbage | ស្ពៃក្ដោប | | | | | | | |
| Cauliflower | ផ្កាខាតណា | | | | | | | |
| Chili | ម្ទេស | | | | | | | |
| Chinese kale | ខាតណាដើម | | | | | | | |
| Chinese mustard | ស្ពៃជើងទា | | | | | | | |
| Choy sum | ស្ពៃចង្កឹះ | | | | | | | |
| Cucumber | ត្រសក់ | | | | | | | |
| Curly mustard | ស្ពៃក្រញាញ់ | | | | | | | |
| Eggplant | ត្រប់ | | | | | | | |
| Green mustard | ស្ពៃខៀវ | | | | | | | |
| Lettuce | សាឡាត | | | | | | | |
| Long bean | សណ្ដែកគួរ | | | | | | | |
| Luffa gourd |ននោង | | | | | | | |
| Round eggplant | ត្រប់មូល | | | | | | | |

# ឧបសម្ព័ន្ធ៤

## ការវិភាគ និងការបង្ហាញព័ត៌មានទីផ្សារ

តារាង និងគំនូសតាងខាងក្រោមគឺជាឧទាហរណ៍នៃលទ្ធផលវិភាគទិន្នន័យដែលអាចត្រូវបានបកស្រាយទៅកសិករក្នុងអំឡុងពេលកិច្ចប្រជុំក្រុមកសិករ។ ទាំងនោះអាចបង្ហាញទៅកសិករនៅក្នុងកិច្ចប្រជុំធំៗដោយគូរលើក្រដាសផ្ទាំងធំ និង/ឬព្រីននៅលើកាតព័ត៌មានអាជីវកម្ម (BIC) ដើម្បីចែកជូនក្នុងអំឡុងពេលកិច្ចប្រជុំ។ ទិន្នន័យទីផ្សារអាចត្រូវបានបកស្រាយ និងប្រែទៅជារូបភាពដោយប្រើប្រាស់ឧបករណ៍ Software ដូចជា Power BI ជាធម្មតា Excel គ្រប់គ្រាន់ដើម្បីវិភាគ និងងាយមើលឃើញទិន្នន័យ។

### ១. ព័ត៌មានក្រុមកសិករ

#### ទីតាំង

| ក្រុមកសិករ | ខេត្ត | ស្រុក | ភូមិ | ចំនួនសមាជិក |
|---|---|---|---|---|
| KRCB-BLK2 (អត្តសញ្ញាណតែ១គត់ ឈ្មោះ ឬចំនួន) | ក្រចេះ | ចិត្របុរី | បុស្សលាវក្រោម | 18 |

#### ក្រុមកសិករ (FG) ដែលបានជ្រើសរើសមុខបន្លែសំខាន់ៗ និងផលិតកម្មថ្មីៗ

| បន្លែសំខាន់ៗ ចំនួន៥មុខដែលត្រូវដាំ | ទំហំដីដាំជាមធ្យម (ម²/កសិករ) | ចំនួនវដ្ត/ឆ្នាំ | ទិន្នផល (គក/ម²) | ចំនួនសមាជិកក្រុមកសិករ | ផលិតកម្មសរុបសម្រាប់កសិករម្នាក់ (តោន/ឆ្នាំ) | ផលិតកម្មសរុបក្នុងក្រុម (តោន/ឆ្នាំ) |
|---|---|---|---|---|---|---|
| ស្ពៃក្ដោប | ២.៥០០ | ១,០ | ២,៤ | ១៣ | ៥,៩ | ៧៦,៩ |
| ត្រសក់ | ១.០៣០ | ១,៧ | ១,៣ | ៦ | ២,៣ | ១៣,៧ |
| ស្ពៃក្រញាញ់ | ២០០ | ២,២ | ១,៣ | ១,៣ | ០,៥ | ៦,៩ |
| ប៉េងប៉ោះ | ៨២០ | ១,១ | ១,៣ | ១,៣ | ១,១ | ១៤,៦ |
| សណ្ដែកកួរ | ៨១៥ | ១,៦ | ១,៥ | ១,៣ | ២,០ | ២៥,៤ |

#### បញ្ហាចំបងៗ និងយុទ្ធសាស្ត្រដំណោះស្រាយសម្រាប់បន្លែនីមួយៗ៖

| បន្លែ | បញ្ហា | យុទ្ធសាស្ត្រដំណោះស្រាយ |
|---|---|---|
| ត្រសក់ | ចំណេះដឹងលើការគ្រប់គ្រងជំងឺ និងសត្វល្អិតនៅមានកម្រិត<br>ខ្វះព័ត៌មានទីផ្សារ | • ណែនាំបច្ចេកវិទ្យាអន្ទាក់លឿងក្នុងចម្ការដាំដុះអាជីព<br>• ជជែកជាមួយអាជីវករ/មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអំពីបរិមាណតម្រូវការ |
| ស្ពៃក្រញាញ់ | ចំណេះដឹងលើការគ្រប់គ្រងជំងឺ និងសត្វល្អិតនៅមានកម្រិត | • ស្វែងរកដំបូន្មានពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/អ្នកលក់ធាតុចូលកសិកម្ម<br>• រកដំណោះស្រាយតំឡើងផ្ទះសំណាញ់ |
| ប៉េងប៉ោះ | ចំណេះដឹងលើការគ្រប់គ្រងជំងឺ និងសត្វល្អិតនៅមានកម្រិត | • ណែនាំបច្ចេកវិទ្យាថ្មី (កាត់ត)<br>• លទ្ធភាពទទួលបានដំណោះស្រាយបច្ចេកទេសផ្ដល់ដោយអ្នកលក់ធាតុចូលកសិកម្ម<br>• ស្វែងរកដំបូន្មានពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ/អ្នកលក់ធាតុចូលកសិកម្ម |
| សណ្ដែកកួរ | កង្វះទឹកនៅក្នុងតំបន់ | • ស្វែងរកការគាំទ្រតំឡើងមធ្យោបាយទឹកស្លាតវៃ |

## ២. ការផ្គត់ផ្គង់ថ្មីៗរបស់ក្រុមកសិករធៀបទៅនឹងគម្លាតផ្គត់ផ្គង់

គម្លាតផ្គត់ផ្គង់គឺមានភាពខុសគ្នារវាងបរិមាណបន្លែដែលអាជីវករបានធ្វើការស្ទង់មតិហើយ មានរបាយការណ៍ថាពួកគេមានតម្រូវការ និងបរិមាណដែលកសិករផលិត និងផ្គត់ផ្គង់ទៅអាជីវករ។

| បន្លែសំខាន់ៗ ចំនួន៥មុខ | តម្រូវការសរុបពីផ្សារចំបងៗចំនួន៦ក្នុងខេត្តក្រចេះ (តោន/ឆ្នាំ) | តម្រូវការសរុបពីផ្សារក្រុងក្រចេះ (តោន/ឆ្នាំ) | ការផ្គត់ផ្គង់សរុបពីក្រុមកសិករ (តោន/ឆ្នាំ) | គម្លាតផ្គត់ផ្គង់ក្នុងផ្សារក្រុងក្រចេះ (តោន/ឆ្នាំ) | គម្លាតផ្គត់ផ្គង់ក្នុងផ្សារចំបងៗចំនួន៦ (តោន/ឆ្នាំ) |
|---|---|---|---|---|---|
| ត្រសក់ | ១.២៥៧ | ២០៩,៥ | ១៣,៧ | ១៩៥,៨ | ១.២៤៣,៣ |
| ស្ពៃក្តោប | ៥៧៧,៧ | ៩៦,៣ | ៧៦,៩ | ១៩,៤ | ៥០០,៨ |
| ប៉េងប៉ោះ | ៣៥៧,៤ | ៥៩,៦ | ១៤,៦ | ៤៥ | ៣៤២,៨ |
| សណ្តែកកួរ | ២៤២,៧ | ៤០,៤ | ២៥,៤ | ១៥ | ២១៧,២ |
| ស្ពៃក្រញាញ់ | ២២១ | ៣៦,៨ | ៦,៩ | ២៩,៩ | ២១៤,១ |















## ៣. បញ្ហាលើបន្លែ១មុខៗ និងចំនួនកសិករដែលប៉ះពាល់

| បញ្ហា | ត្រសក់ | ស្ពៃក្ដោប | ប៉េងប៉ោះ | សណ្ដែកកួរ | ស្ពៃក្រញាញ់ | សរុប |
|---|---|---|---|---|---|---|
| ទឹកជំនន់ | ៣ | – | ៧ | ៧ | ៥ | ១៧ |
| ខ្វះព័ត៌មានតម្រូវការទីផ្សារ | ៥ | ៨ | – | – | ១ | ១ |
| ចំណេះដឹងលើការគ្រប់គ្រងជំងឺ និងសត្វល្អិតនៅមានកម្រិត | ១០ | – | ១៤ | ១៦ | ៦ | ៥២ |
| កង្វះទឹកនៅក្នុងតំបន់ | ៣ | – | ២ | ៣ | ២ | ១០ |
| ពេលវេលាសរុប | ២១ | ៨ | ១៨ | ២៦ | ១៤ | ៨០ |

## ៤. តម្រូវការធៀបនឹងការផ្គត់ផ្គង់បន្លែ ( គក/ខែ )




## ៥. តម្លៃប៉ាន់ស្មានក្នុង១មុខដំណាំ ( ដុល្លារ/គក )

| តម្លៃប៉ាន់ស្មាន ( ដុល្លារ/គក ) | | ត្រសក់ | សណ្ដែកកួរ | ស្ពៃក្ដោប | ប៉េងប៉ោះ | ស្ពៃក្រញាញ់ |
|---|---|---|---|---|---|---|
| តម្លៃលក់នៅចម្ការ | ខ្ពស់ | ០,២៥ | ០,៥០ | ០,៣០ | ០,៣០ | ០,៣០ |
| | ទាប | ០,១២ | ០,២៥ | ០,១៥ | ០,១០ | ០,១០ |
| តម្លៃលក់ដុំ | ខ្ពស់ | ០,៣០ | ០,៦០ | ០,៤០ | ០,៥០ | ០,៤០ |
| | ទាប | ០,២០ | ០,៤០ | ០,២០ | ០,១៥ | ០,២០ |
| តម្លៃលក់រាយ | ខ្ពស់ | ០,៥០ | ១,០០ | ០,៧៥ | ១,២៥ | ០,៦០ |
| | ទាប | ០,៣០ | ០,៦០ | ០,២៥ | ០,៣០ | ០,៣០ |

# ឧបសម្ព័ន្ធ៥

## របៀបវារៈកិច្ចប្រជុំក្រុមកសិករ

គម្លាតផ្គត់ផ្គង់គឺមានភាពខុសគ្នារវាងបរិមាណបន្លែដែលអាជីវករបានធ្វើការស្ទង់មតិហើយ មានរបាយការណ៍ថាពួកគេមានតម្រូវការ និងបរិមាណដែលកសិករផលិត និងផ្គត់ផ្គង់ទៅអាជីវករ។

| កាលវិភាគ | សកម្មភាព | អ្នកទទួលខុសត្រូវ | កំណត់ចំណាំ |
|---|---|---|---|
| 8:00 am | ស្វាគមន៍ និងការណែនាំ | តំណាងក្រុមកសិករ ឬបុគ្គលិកមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | |
| 8:15 am | ល្បែងកំសាន្ត | បុគ្គលិក | |
| 8:45 am | តួនាទី និងទំនួលខុសត្រូវក្នុងការផ្សារភ្ជាប់ទីផ្សារ | អ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្ម | បទបង្ហាញជាមួយសំណួរ និងចម្លើយ |
| 9:15 am | បទបង្ហាញព័ត៌មានទីផ្សារ | អ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្ម | បទបង្ហាញជាមួយសំណួរ និងចម្លើយ |
| 9:45 am | ការដើរតួសម្តែងរវាងកសិករដើម្បីស្វែងយល់ពីទីផ្សារ | បុគ្គលិក | ការសម្តែងជាក្រុម |
| 10:00 am | ការពិភាក្សា | បុគ្គលិក | ពិនិត្យគំរូផែនការអាជីវកម្មក្រុមកសិករ ព័ត៌មានជំនួយការសម្របសម្រួល និងសំណួរ ចម្លើយ |
| 10:45 am | ការណែនាំរបៀបរៀបចំផែនការផលិតកម្ម | អ្នកជំនាញទីផ្សារ | |
| 12:00 pm | ធ្វើការជាក្រុម | ក្រុមកសិករ | ការស្ទង់មតិម្នាក់ៗ |
| 12:15 pm | បទបង្ហាញនៃផែនការផលិតកម្មនីមួយៗ | ក្រុមកសិករ | |
| 12:30 pm | ការប្រៀបធៀបផែនការផលិតកម្មជាមួយព័ត៌មានទីផ្សារ និងការកែតម្រូវ | អ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្ម | |
| | កិច្ចព្រមព្រៀង និងបិទកិច្ចប្រជុំ | | |

### ធនធានដែលត្រូវការ

ធនធានខាងក្រោមគឺមានភាពចាំបាច់សម្រាប់កិច្ចប្រជុំនេះ៖

- សកម្មភាពល្បែងកំសាន្ត
- ឯកសារបទបង្ហាញនីមួយៗនៃសិក្ខាសាលារួមមាន៖
    - ប្រធានបទ
    - គោលបំណង
    - របៀបវារៈ
    - ការណែនាំល្បែងកំសាន្ត
    - បទបង្ហាញ 'តួនាទី និងទំនួលខុសត្រូវ'
    - បទបង្ហាញ 'កសិករជាសហគ្រិន'
    - បទបង្ហាញ 'ព័ត៌មានជំនួយសម្រាប់សម្របសម្រួលផែនការអាជីវកម្មក្រុមកសិករ'
    - ការណែនាំរបៀបដើរតួសម្តែង
    - ការណែនាំធ្វើការស្ទង់មតិ
    - បញ្ចប់បទបង្ហាញ
- កុំព្យូទ័រសម្រាប់អ្នកសម្របសម្រួល ប្រូជិកទ័រ និងផ្ទាំងបង្ហាញ
- ឯកសារចែកជូននៃគំរូការរៀបចំផែនការអាជីវកម្មក្រុមកសិករ (៦ច្បាប់ក្នុង១សិក្ខាសាលា ដែល៤ច្បាប់សម្រាប់អ្នកចូលរួម និង២ច្បាប់សម្រាប់ជំនួយបន្ថែម)
- ឯកសារណែនាំការដើរតួសម្តែង (៦ច្បាប់ក្នុង១សិក្ខាសាលា ដែល៤ច្បាប់សម្រាប់អ្នកចូលរួម និង២ច្បាប់សម្រាប់ជំនួយបន្ថែម)
- ក្តារខៀន និងហ្វឺត ឬក្រដាសផ្ទាំងធំជាមួយនឹងជើងទម្រ
- ស្កុត
- ក្រដាសព័ណកត់ចំណាំ (Post-It notes)

# ឧបសម្ព័ន្ធ៦

## ការណែនាំការបណ្តុះបណ្តាល (ការដើរតួសម្តែង) សម្រាប់កិច្ចប្រជុំរៀបចំផែនការអាជីវកម្មក្រុមកសិករ

ការណែនាំនេះផ្តល់ការបង្ហាញអំពីរបៀបបណ្តុះបណ្តាលក្រុមការងាររបស់អ្នកដើម្បីធ្វើការសម្របសម្រួលកិច្ចប្រជុំរៀបចំផែនការអាជីវកម្មជាមួយក្រុមកសិករ (FGBP meeting)។

### ណែនាំសម្រាប់គ្រូបណ្តុះបណ្តាល៖

១. ពន្យល់ទៅក្រុមទាំងមូលអំពីរបៀបដើរតួសម្តែងមានដំណើរការដូចម្តេច (អ្នកអាចប្រើស្លាយបទបង្ហាញ)។

២. ស្នើសុំអ្នកស្ម័គ្រចិត្តអោយសម្របសម្រួលមុនគេ។ អញ្ជើញអ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្មដែលស្ម័គ្រចិត្តចេញពីបន្ទប់ ហើយអោយគាត់ដឹងថាអ្នកនឹងចេញមកក្រៅ៥នាទីទៀតដើម្បីផ្តល់ការណែនាំ។

៣. រក្សារនៅក្នុងបន្ទប់ និងបែងចែកតួនាទីរបស់កសិករ (មើលនៅខាងក្រោម) ជាក្រុម។ ចាត់តាំងតួនាទីរបស់កសិករម្នាក់ៗ។ ប្រាប់ពួកគេអោយអានលើការពិពណ៌នា និងសួរមកអ្នកអំពីចំណុចដែលមិនច្បាស់។ ផ្តល់ព័ត៌មាននេះទៅអ្នកគ្រប់គ្នា៖ ពួកគេគួរតែលើកឡើងនូវបញ្ហាក្នុងអំឡុងពេលសម្តែង ប៉ុន្តែបញ្ហាទាំងនោះគួរតែមិនពិបាកពេក។ ជាទូទៅយើងចង់អោយអ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្មមានបទពិសោធន៍ជាវិជ្ជមាន។

៤. ឥឡូវចេញទៅក្រៅបន្ទប់ និងរៀបចំអ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្មដែលជាសិក្ខាកាម។ រំឭកពីតួនាទីជាមួយគាត់។ រំឭកគាត់ថាវាមានសារៈសំខាន់ក្នុងការបង្កើតកិច្ចព្រមព្រៀងក្នុងចំណោមកសិករជាជាងការពន្លឿនតាមរយៈគំរូរៀបចំផែនការអាជីវកម្មជាមួយក្រុមកសិករ។ ផ្តល់ដំបូន្មានដល់គាត់អោយពឹងពាក់លើអ្នកដឹកនាំក្រុមកសិករដើម្បីជួយរក្សាកិច្ចប្រជុំប្រកបដោយភាពវិជ្ជមាន និងបោះជំហានទៅមុខ។

៥. អនុវត្តន៍ការសម្តែងដូចពណ៌នាខាងក្រោម៖

a. ការអនុវត្ត១០នាទី

b. ការផ្តល់មតិកែលម្អ៥នាទី

- តើចំណុចណាខ្លះដែលអ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្មធ្វើបានល្អ?
- តើចំណុចណាខ្លះដែលអ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្មនឹងធ្វើអោយប្រសើរពេលក្រោយ?

c. អនុវត្តន៍វិលជុំពីរទៅបីដងអាស្រ័យលើពេលវេលាដែលមាន

d. ទីបញ្ចប់ព្យាយាមបង្កើតជាបញ្ជីនៃការអនុវត្តប្រសើរបំផុតជាមួយក្រុមទាំងមូល។

### ការណែនាំសម្រាប់សិក្ខាកាម៖

១. សមាជិកក្រុមនីមួយៗដែលត្រូវបានបណ្តុះបណ្តាលជាអ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្ម នឹងត្រូវបានសួរដើម្បីអោយបំពេញផ្នែកមួយឬច្រើននៃការរៀបចំផែនការក្រុមកសិករទាំងមូល។

២. អ្នកនឹងមានពេល១០នាទីដើម្បីអនុវត្តការសម្របសម្រួលខណៈពេលបុគ្គលិកដទៃទៀតដើរតួជាសមាជិកក្រុមកសិករ។

៣. អនុវត្តន៍ដោយមិនមានការប្រញាប់ប្រញាល់។ សម្របសម្រួលលើគំរូការរៀបចំផែនការអាជីវកម្មក្រុមកសិករកាន់តែច្រើនតាមដែលអាចធ្វើទៅបានក្នុងរយៈពេល១០នាទី។ វាមានសារៈសំខាន់ដែលក្រុមកសិករឯកភាពលើធាតុទាំងឡាយនៃផែនការអាជីវកម្មជាជាងការបំពេញលើការរៀបចំផែនការអាជីវកម្មក្រុមកសិករ។

៤. នៅក្នុងការសម្តែង អ្នករួមការងាររបស់អ្នកដែលដើរតួជាកសិករ នឹងសួរសំណួរពិបាកៗ។ ប្រឹងប្រែងអោយអស់ពីសមត្ថភាពដើម្បីឆ្លើយពួកគេ និងបំពេញផ្នែករបស់អ្នកនៃការរៀបចំផែនការអាជីវកម្មក្រុមកសិករ។

៥. ក្រោយពេលការសម្របសម្រួល១០នាទី ក្រុមនឹងផ្តល់មតិកែលម្អរយៈពេល៥នាទីនៅលើអ្វីដែលអ្នកធ្វើបានល្អ និងអ្វីគួរពង្រឹងបន្ថែម។

៦. នៅចុងបញ្ចប់នៃការសម្តែង ធ្វើការរួមគ្នាជាមួយសិក្ខាកាមដទៃទៀតដើម្បីបង្កើតបញ្ជីនៃការអនុវត្តប្រសើរបំផុតក្នុងការបង្ហាញផ្លូវក្រុមឆ្ពោះទៅមុខ។

- តើការអនុវត្តប្រសើរបំផុតអ្វីខ្លះដែលយើងគួររក្សាទុកក្នុងចិត្តនៅពេលសម្របសម្រួលរៀបចំផែនការអាជីវកម្មក្រុមកសិករ?
- តើឧបសគ្គ ឬស្ថានភាពលំបាកសំខាន់ៗអ្វីខ្លះដែលយើងគួរព្យាយាមជៀសវាងនៅពេលសម្របសម្រួលរៀបចំផែនការអាជីវកម្មក្រុមកសិករ?

## តួនាទីរបស់កសិករ៖

**កសិករទី១៖** អ្នកគឺជាអ្នកដឹកនាំក្រុមកសិករ។ អ្នកចាប់អារម្មណ៍អំពីការធ្វើការងារជាមួយគ្នាលើផែនការអាជីវកម្មមួយ និងចូលចិត្តគំនិតនៃការរៀបចំផែនការដោយផ្អែកលើព័ត៌មានទីផ្សារពីអាជីវករ។ ប្រសិនកសិករដទៃទៀតលើកឡើងនូវសំណួរ ឬការបារម្ភផ្សេងៗ សូមព្យាយាមជួយអ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្ម និងអោយពួកគេផ្តោតលើការបំពេញផែនការអាជីវកម្ម។

**កសិករទី២៖** អ្នកសប្បាយចិត្តបានក្លាយជាសមាជិកក្រុមកសិករ។ ជាពិសេសអ្នកចូលចិត្តការបណ្តុះបណ្តាលបន្ថែម និងជំនួយខាងកសិកម្មដែលអ្នកទទួលបានតាមរយៈគម្រោង។ ប៉ុន្តែនៅពេលនិយាយដល់ជម្រើសអំពីដំណាំអ្វីដែលត្រូវដាំ អ្នកពិតជាមានភាពឯករាជ្យ។ អ្នកមានការជំទាស់នឹងការសម្របសម្រួលផលិតកម្មជាក្រុម ដូច្នេះអ្នកមិនសូវសហការជាមួយអ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្ម (ប៉ុន្តែសូមកុំតានតឹងពេក)។

**កសិករទី៣៖** អ្នកសប្បាយចិត្តក្នុងការរៀបចំផែនការអាជីវកម្មជាមួយកសិករដទៃទៀតទាំងអស់នៅក្នុងក្រុម។ ទោះបីយ៉ាងណាក៏ដោយ អ្នកធ្វើការជំទាស់គំនិតថាផ្សារគួរតែកំណត់ដំណាំអ្វីដែលត្រូវដាំ។ អ្នកមានមុខដំណាំដែលជាចំណង់ចំណូលចិត្តរបស់អ្នក ហើយអ្នកមានបំណងដាំដំណាំទាំងនោះ ពីព្រោះអ្នកមានទំលាប់លើពួកវា និង ដំណាំទាំងនោះងាយស្រួលដាំ។ អ្នកគួរតែប្រឆាំងនឹងគំនិតប្រើប្រាស់ព័ត៌មានទីផ្សារសម្រាប់ធ្វើការសម្រេចចិត្តលើការផលិត ប៉ុន្តែទីបញ្ចប់អ្នកគួរតែយល់ព្រមដោយស្ទាក់ស្ទើរចិត្តក្នុងការធ្វើអ្វីដែលក្រុមចង់បាន។

**កសិករទី៤៖** អ្នកចូលចិត្តគំនិតរៀបចំផែនការអាជីវកម្ម និងដាំដុះដំណាំថ្មីៗដែលមានតម្រូវការខ្ពស់។ ទោះយ៉ាងណាក៏ដោយ អ្នកបារម្ភអំពីការដាំដុះដំណាំខុសៗគ្នា ជាពិសេសដំណាំដែលអ្នកមិនធ្លាប់ដាំ។ ធ្វើដូចម្តេចប្រសិនគ្រាប់ពូជមានដំណុះមិនល្អ? ប្រសិនអ្នកធ្វើទៅខុស និងការប្រមូលផលដំបូងត្រូវបានបំផ្លាញ? ប្រសិនកត្តាចង្រៃបំផ្លាញផលដំណាំ? អ្នកគួរតែប្រឈមដោយថ្នមៗទៅនឹងគំនិតសាកល្បងអ្វីមួយថ្មី។

# ឧបសម្ព័ន្ធ៧

## ការរៀបចំផែនការអាជីវកម្មក្រុមកសិករ

កាលបរិច្ឆេទ៖ ____________________

### ផ្នែកទី១៖ ព័ត៌មានអាជីវកម្មមូលដ្ឋាន

| | |
|---|---|
| ១. ឈ្មោះក្រុម | |
| ២. ឈ្មោះអ្នកតំណាងក្រុម | |
| ៣. អាសយដ្ឋាន និងលេខទូរស័ព្ទ | |
| ៤. ចំនួនសមាជិកក្រុម | |
| ៥. មុខដំណាំផ្តោតសំខាន់ | |
| ៦. ផ្ទៃដីផលិតកម្មសរុប | |
| ៧. ដើមទុនក្រុមសរុបសម្រាប់បើកអាជីវកម្ម | |
| ៨. ពេលវេលានៃអាជីវកម្ម<br>(រយៈពេលដាំដុះ និងចំនួនវដ្តក្នុង១មុខដំណាំ) | |

### ផ្នែកទី២៖ គោលបំណងនៃអាជីវកម្ម

ពណ៌នាអំពីគោលបំណងនៃអាជីវកម្មរបស់អ្នក។ ឧទាហរណ៍៖

- បង្កើនផលិតកម្មដំណាំដើម្បីបំពេញតម្រូវការទីផ្សារ និងបញ្ចៀសតម្លៃទាប
- ប្រមូល និងបង្កើតផែនការផលិតកម្មដំណាំ
- គាំទ្រគ្នាក្នុងការលក់ និងដំណើរការចរចាជាមួយអាជីវករ

### ផ្នែកទី៣៖ ផែនការផលិតកម្ម និងការធ្វើទីផ្សារ

**ការជ្រើសរើសមុខដំណាំ**

មុនពេលរៀបចំផែនការផលិតកម្ម ការជ្រើសរើសប្រភេទដំណាំគឺមានសារៈសំខាន់ណាស់។ មុនពេលធ្វើការជ្រើសរើសប្រភេទដំណាំ លើកទឹកចិត្តសមាជិកក្រុមអោយគិតដល់តម្រូវការទីផ្សារជាក់ស្តែងជាជាងផ្តោតទៅលើកង្វល់ ឬស្ថានភាពផ្ទាល់ខ្លួនដូចជា ភាពលំបាកនៃការដាំដុះដំណាំថ្មី រយៈពេលដែលត្រូវការ មិនមានប្រភពទឹកស្រោចស្រពលើដីដំណាំជាក់លាក់ណាមួយ ពេលវេលាប្រមូលផលជាដើម។ ក្រុមអាចជ្រើសរើសប្រភេទដំណាំ៣ទៅ៥មុខជាអាទិភាពសម្រាប់ការរៀបចំផែនការអាជីវកម្ម ប៉ុន្តែសមាជិកទាំងឡាយក៏អាចជ្រើសរើសដាំដុះដំណាំដទៃទៀតផងដែរ។

**ផែនការផលិតកម្ម**

អ្នកសម្របសម្រួលអាជីវកម្មទៅអាជីវកម្មជួយសមាជិកក្រុមចងក្រងប្រតិទិនដាំដុះ និងប្រមូលផលសម្រាប់មុខដំណាំដែលបានជ្រើសរើសដើម្បីបំពេញតម្រូវការទីផ្សារជាក់ស្តែង។ បង្កើតប្រតិទិនមុខដំណាំសម្រាប់កសិករនីមួយៗ គណនាទិន្នផលសរុប កំណត់កាលបរិច្ឆេទលក់ជាក់លាក់ និងធានាថាពួកគេមិនដាំដំណាំដូចគ្នាក្នុងពេលដំណាលគ្នា ដែលអាចនាំអោយមានផលិតកម្មលើស និងការផ្គត់ផ្គង់ជន់។ សរុបលទ្ធផល/ទិន្នន័យនៃដំណាំនីមួយៗដែលត្រូវបានព្រមព្រៀងដោយសមាជិកក្រុមនៅក្នុងតារាងខាងក្រោម៖

| មុខដំណាំ | ផលិតកម្មសរុប | ចំនួនសមាជិកពាក់ព័ន្ធ | បរិមាណប្រមូលផលក្នុង១ថ្ងៃ (គីក) | ពេលវេលាប្រមូលផល |
|---|---|---|---|---|
| | | | | |
| | | | | |
| | | | | |
| | | | | |

សមាជិកក្រុមនីមួយៗគួរតែមានផែនការផលិតកម្មច្បាស់លាស់ជាមួយកាលវិភាគជាក់លាក់ដើម្បីដាំ និងប្រមូលផល។ រៀបចំកាលបរិច្ឆេទបណ្ដុះកូន រហូតដល់ប្រមូលផល ព្រមទាំងគណនាផលិតកម្មដែលរំពឹងទុក។ ប្រសិនបើអ្នកស្គាល់ផ្ទៃដីដាំដុះនៃសមាជិកនីមួយៗ ប្រើប្រាស់តារាងយោងដើម្បីធ្វើការប៉ាន់ប្រមាណផលិតកម្មលើដីគ្រោងដាំដុះនោះ៖

ផលិតកម្មរំពឹងទុក (តោន) = ផ្ទៃដីគ្រោងដាំ (ម២) / ១០០០០ x ទិន្នផលយោង

Expected production (tonnes) = plot area ($m^2$) / 10,000 X reference yield

ឧទាហរណ៍លើដំណាំត្រសក់ និងផែនការផលិតកម្មប្រហាក់ប្រហែលដូចបង្ហាញខាងក្រោមនេះ៖

| សមាជិក | ម២ | ពេលវេលាបណ្ដុះកូន | ពេលវេលាប្រមូលផល | ផលិតកម្មរំពឹងទុក (តោន) |
|---|---|---|---|---|
| ភិន ផូ | ៣០០០ | ០១-០២-២០២២ | រៀងរាល់ថ្ងៃពី ២៨-០៤-២០២២ | ១២ |
| តុង ដាំ | ១៦០០ | ១៥-០២-២០២២ | រៀងរាល់ថ្ងៃពី ១៤-០៥-២០២២ | ៦,៤ |
| | | | | |
| | | | | |

## ផែនការទីផ្សារ

| មុខដំណាំ | កន្លែងត្រូវលក់ | ឈ្មោះអ្នកទិញ | បរិមាណត្រូវលក់ | ពេលត្រូវលក់ | តម្លៃរំពឹងទុក/គក |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

## ផែនការហិរញ្ញវត្ថុក្រុម

ផែនការហិរញ្ញវត្ថុដាច់ដោយឡែកមួយអាចត្រូវបានបង្កើតសម្រាប់កសិករម្នាក់ៗផ្អែកលើការចំណាយជាក់ស្ដែង ដែលបានធ្វើការគណនារួមគ្នាជាមួយកសិករទាំងអស់។ សម្រាប់ក្រុមទាំងមូល ចំណូល និងចំណាយត្រូវបានវិភាគដោយផ្អែកលើព័ត៌មានឯកសារយោង (សូមមើលការរៀបចំថវិកាមុខដំណាំនៅក្នុង ឯកសារបៀបណែនាំ) ដោយប្រើប្រាស់ព័ត៌មានមុខដំណាំដែលបានជ្រើសរើសពីសមាជិកម្នាក់ៗ។

| មុខដំណាំ | ផលិតកម្មក្រុម (គក) | ចំណាយ | | ចំណូល | | ចំណូលដុល (ដុល្លារ) |
|---|---|---|---|---|---|---|
| | | ថ្លៃដើម (ដុល្លារ/គក) | សរុប (ដុល្លារ) | តម្លៃ (ដុល្លារ/គក) | សរុប (ដុល្លារ) | |
| ត្រសក់ | ៨០០០ | ០,១០ | ៨០០០ | ០,២៥ | ២០.០០០ | ១២.០០០ |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

**បញ្ហាប្រឈមរបស់ក្រុម៖**

| បញ្ហាប្រឈម | ដើមហេតុ/ឫសគល់បញ្ហា |
|---|---|
| | |
| | |
| | |

សកម្មភាពរួមគ្នាដើម្បីដោះស្រាយបញ្ហា៖

| បញ្ហាប្រឈម | សកម្មភាព | ពេលវេលា | ភាគីពាក់ព័ន្ធ |
|---|---|---|---|
| | | | |
| | | | |
| | | | |

## ប្រភពទុនសម្រាប់វិនិយោគ

សូមពន្យល់អំពីប្រភពទុនរបស់អ្នក៖ ខ្ចីមានការប្រាក់ពីសំណាក់អ្នកចងការ ស្ថាបនមីក្រូហិរញ្ញវត្ថុ ឬធនាគារ ការជួយឧបត្ថម្ភពីកូន ឬសមាជិកគ្រួសារដទៃទៀត ចំណូលពីការចិញ្ចឹមសត្វ ធ្វើស្រែ ឬសកម្មភាពកសិកម្មដទៃទៀត ។ល។

ដើមទុនដែលត្រូវការសរុប៖ ______________________________

ទុនមានក្នុងដៃសរុប៖ ______________________________

ទុនរំពឹងទុកពីភាគីទីបី៖ ______________________________

| ប្រភពទុន | ចំនួន (ដុល្លារ) | គោលបំណង |
|---|---|---|
| កម្ចីធនាគារ | | |
| ប្រាក់ខែ | | |
| ប្រាក់ជួយឧបត្ថម្ភ | | |
| ផ្សេងទៀត | | |
| ប្រភពទុន | | |

សូមពិពណ៌នាអំពីហានិភ័យដែលអាជីវកម្មរបស់អ្នកប្រឈម (ផលិតកម្ម និងការលក់)។

______________________________

______________________________

______________________________

តើអ្នកមានផែនការអ្វីខ្លះដើម្បីកាត់បន្ថយហានិភ័យទាំងនោះ?

______________________________

______________________________

______________________________

ធ្វើនៅ __________ ថ្ងៃទី __________ ខែ __________ ឆ្នាំ __________

ស្នាមមេដៃសមាជិកក្រុម

# ឧបសម្ព័ន្ធ៨

## កត្តាសំខាន់ៗគួរពិចារណាសម្រាប់ការជ្រើសរើសមុខដំណាំ

### ៨. ចំណុចគន្លឹះសម្រាប់ការជ្រើសរើសមុខដំណាំ

នៅពេលកសិករដាំបន្លែត្រៀមរៀបចំធ្វើផែនការផលិតកម្ម ឬរៀបចំបង្កើតកិច្ចសន្យាជាមួយក្រុមហ៊ុនប្រមូលទិញ ពួកគេគួរពិចារណាអំពី៖ តម្រូវការកម្លាំងពលកម្មដែលមាន ទិន្នផល តម្លៃ ភាពប្រឈម-ហានិភ័យនឹងជំងឺ និងផលចំណេញជាដើម។ ព័ត៌មានលម្អិតមានដូចខាងក្រោម៖

### ១. សម្ភារ និងកម្លាំងពលកម្ម

អ្នកគួរគិតគូរអំពីវិធីគ្រប់គ្រងមុខដំណាំដែលអ្នកត្រូវជ្រើសរើសដាំ។ ចំពោះកសិករពាក់កណ្ដាលអាជីព អ្នកគួរពិនិត្យលើតម្រូវការកម្លាំងពលកម្មទាំងកម្លាំងពលកម្មក្នុងគ្រួសារដែលមាន និងកម្លាំងពលកម្មដែលត្រូវជួលពីខាងក្រៅ។ ក្នុងករណីអ្នកមិនមានកម្លាំងពលកម្មគ្រប់គ្រាន់ អ្នកអាចពិចារណាស្វែងរកជម្រើសបច្ចេកវិទ្យាផ្សេងៗដូចជាគ្រឿងម៉ាស៊ីនដែលមានតម្លៃសមរម្យអាចលៃលកទិញបាន។ ប្រសិនបើតម្លៃកម្លាំងពលកម្មខ្ពស់ អ្នកគួរជ្រើសរើសមុខដំណាំដែលងាយស្រួលប្រមូលផល ហើយចំណាយពេលខ្លីក្នុងការបញ្ចប់វដ្ដដំណាំនោះ។ ឧទាហរណ៍ ការប្រមូលផលម្ទេសទាមទារកម្លាំងពលកម្មច្រើន ហើយប្រើប្រាស់រយៈពេលច្រើនថ្ងៃសម្រាប់បេះម្ទេសទុំពេញរូបរាងពីព្រោះម្ទេសមិនទុំចំពេលដំណាលគ្នានោះទេ។ អ្នកចាំបាច់ត្រូវចំណាយពេលបេះម្ទេសណាដែលទុំស្មើរជារៀងរាល់ថ្ងៃ និងត្រូវរង់ចាំរហូតដល់ម្ទេសដទៃទៀតទុំពេញលក្ខណៈទើបអាចបេះបាន។ ក្នុងករណីនេះ អ្នកចាំបាច់ត្រូវពិចារណា និងពិនិត្យមើលកម្លាំងពលកម្មដែលមាន ព្រមទាំងការចំណាយសមរម្យ។ ឈេនស្នើអោយធ្វើការគណនាលើការចំណាយសម្រាប់កម្លាំងពលកម្ម និងផលិតកម្ម រួមទាំងការបង្កើតកិច្ចសន្យាទិញលក់។

### ២. ប្រភពទឹក

ប្រសិនគ្មានប្រភពទឹក គឺមិនអាចដាំដុះបន្លែបានទេពិសេសនៅរដូវក្ដៅ។ កសិករដាំបន្លែគួរយល់ដឹងអោយបានច្រើនអំពីតម្រូវការទឹកសម្រាប់ស្រោចស្រពដំណាំជាក់លាក់នីមួយៗ បើពុំដូចនោះទេពួកគេនឹងប្រឈមបញ្ហានៅពេលជ្រើសរើសដំណាំដែលត្រូវប្រើប្រាស់ទឹកច្រើនដើម្បីដាំ។ កសិករជាច្រើនកំពុងប្រឈមនឹងកង្វះខាតទឹកក្នុងអំឡុងពេលរដូវក្ដៅ។ ក្នុងករណីនេះ អ្នកដាំដុះគួរជៀសវាងដាំបន្លែស្លឹកដែលភាគច្រើនត្រូវការទឹកទៀងទាត់ក្នុងផលិតកម្ម។ អ្នកដាំអាចប្រើប្រាស់សុលឡាបូមទឹក/ម៉ាស៊ីនបូមទឹក/ឬអគ្គិសនី ដើម្បីបូមទឹកពីរ៉េស៊ីវ៉រ ស្រះ នឹងទន្លេជាដើម។ ក្នុងករណីនេះពួកគេចាំបាច់ត្រូវមានថវិកាក្នុងដៃដើម្បីទិញសម្ភារទាំងនោះ។ កសិករគួរដាំដំណាំឆ្លាស់ និងជ្រើសរើសមុខដំណាំផ្អែកទៅលើប្រភពទឹកដែលខ្លួនមាន និងជំនួសការដាំដុះបន្លែស្លឹកទៅជាដំណាំផ្លែដូចជា ត្រសក់ ឬត្រប់ ដោយសារដំណាំទាំងនេះមិនត្រូវការបរិមាណទឹកច្រើន ហើយក៏មិនត្រូវការស្រោចស្រពញឹកញាប់ដែរ។

### ៣. ទិន្នផល

កសិករគួរយល់ដឹងអោយបានច្បាស់អំពីទិន្នផលដំណាំមុនពេលពួកគេជ្រើសរើសប្រភេទដំណាំនោះមកដាំ ហើយពួកគេអាចរៀនសូត្រដកស្រង់បទពិសោធន៍ពីការដាំដុះដំណាំនោះ២ដងក្នុង១ឆ្នាំតាមការប្រែប្រួលអាកាសធាតុគឺនៅរដូវប្រាំង និងរដូវវស្សា។ ដំណាំមួយចំនួនទទួលបានទិន្នផលខ្ពស់នៅរដូវប្រាំងប៉ុន្តែមានតម្លៃទាប ដំណាំមួយចំនួនទៀតមានភាពប្រថុយប្រថានក្នុងការដាំដុះប៉ុន្តែមានតម្លៃខ្ពស់។ អ្នកគួរធ្វើការគណនាចំនួនគីឡូក្រាមក្នុងពេលប្រមូលផលម្ដងៗ និងនៅរដូវការមួយណា។ ប្រសិនដំណាំដែលត្រូវបានជ្រើសរើសអាចផ្ដល់ទិន្នផលខ្ពស់ និងតម្លៃល្អ កសិករអាចពិចារណាដាំដុះដំណាំនោះនៅលើដីដែលខ្លួនគ្រោងដាំបាន។

កសិករចាំបាច់ត្រូវដឹងថាតើពួកគេអាចរកប្រាក់ចំណេញបានទេប្រសិនបើដាំដំណាំនេះ ឬដំណាំនោះ ឬ ដាំពូជថ្មី។ គម្រោងឈេនបានផ្ដល់បញ្ជីព័ត៌មានសំខាន់ៗសម្រាប់ជាជំនួយដល់ពួកគេដើម្បីធ្វើការសម្រេចចិត្ត។

### តម្លៃ

តម្លៃគឺជាកត្តាគន្លឹះសម្រាប់រៀបចំផែនការអាជីវកម្ម។ តម្លៃបន្លែឡើងឬចុះគឺអាស្រ័យលើតម្រូវការទីផ្សារ និងតាមរដូវលក់បានថ្លៃ ឬបានថោកផងដែរ។ ព័ត៌មានទីផ្សារ អាចប្រមូលបានពីអាជីវករលក់ផ្ទាល់នៅផ្សារ ដូចជាតម្លៃក្នុង១គីឡូក្រាម និងបរិមាណតម្រូវការក្នុង១ថ្ងៃ ឬតាមរយៈការស្រាវជ្រាវតម្លៃទីផ្សារដូចបង្ហាញខាងលើ។ ក្នុងអំឡុងពេលរៀបចំផែនការអាជីវកម្ម គួរមានរៀបចំល្បែងកំសាន្តសម្រាប់កសិករដើម្បីសម្ដែង និងរៀនសូត្រអំពី**ថ្លៃដើមផលិតកម្ម**។ ឧទាហរណ៍៖ តើត្រូវចំណាយប៉ុន្មានដើម្បីផលិតបានស្ពៃចង្កឹះ១គីឡូក្រាម? អនុញ្ញាតអោយកសិករធ្វើការប៉ាន់ស្មាន និងគណនាថ្លៃដើម ព្រមទាំងការចំណាយផ្សេងៗសម្រាប់ដំណាំស្ពៃចង្កឹះក្នុង១វដ្ដផលិតកម្ម ជាពិសេសអោយពួកគេធ្វើបញ្ជីតម្លៃគ្រាប់ពូជការចំណាយសម្រាប់ផ្ទៃដី១០០ម២។ ធ្វើការប៉ាន់ប្រមាណទិន្នផលទុកជាមុន ហើយអ្នកធ្វើការចែកចំនួនគីឡូក្រាមនៃផលិតកម្មដោយការចំណាយសរុប នោះអ្នកនឹងឃើញតម្លៃចំណាយរបស់អ្នកក្នុង១គីឡូក្រាម។

## ៤. សត្វល្អិតចង្រៃ និងជំងឺ

ការគ្រប់គ្រងសត្វល្អិតចង្រៃ និងជំងឺ គឺជាការវិធានការចាំបាច់សម្រាប់ដោះស្រាយរាល់ការខូចខាតលើដំណាំបន្លែរបស់អ្នក។ អ្នកគួររៀបចំ និងស្វែងយល់ថា តើប្រភេទសត្វល្អិតបំផ្លាញ និងជំងឺអ្វីខ្លះដែលកើតឡើងជារឿយៗលើដំណាំដែលអ្នកជ្រើសរើសដាំ។ កសិករគួរពិចារណាជ្រើសរើសពូជណាដែលសុទ្ធល្អ ធន់ទ្រាំនឹងជំងឺ និងសត្វល្អិត ជាដើម។ ព័ត៌មានស្តីពីកត្តាសត្វល្អិត និងជំងឺ អាចសាកសួរទៅអ្នកបច្ចេកទេស ញាតិជិតខាងរបស់អ្នក បទពិសោធន៍ផ្ទាល់ខ្លួន និងការសង្កេតផ្សេងៗ។

## ៦. មុខដំណាំ និងលក្ខណៈវិនិច្ឆ័យសំខាន់។

ការរៀបចំផែនការផលិតកម្ម គឺជាដំណើរការសំខាន់មួយដែលត្រូវគិតគូរ ដើម្បីធានាបាននូវផលចំណេញ និងចីរភាព។ ការរៀបចំផែនការផលិតកម្ម លើកទឹកចិត្តអោយកសិកររៀបចំប្រតិទិនផលិតកម្ម និងការប្រមូលផល ព្រមទាំងធ្វើការប៉ាន់ស្មានពេលវេលាដែលពួកគេទទួលបានបរិមាណទិន្នផលនៃដំណាំនីមួយៗ។ វិធីនេះគឺជាការផ្គូផ្គងរវាងការផ្គត់ផ្គង់ និងតម្រូវការ ព្រមទាំងកាត់បន្ថយហានិភ័យនៃការផ្គត់ផ្គង់លើសតម្រូវការ និងផ្តល់ព័ត៌មានពាក់ព័ន្ធទៅអ្នកទិញសម្រាប់ការប្រមូលផ្តុំផលិតផល និងមធ្យោបាយដឹកជញ្ជូន។

**តារាងខាងក្រោមគឺជាលក្ខណៈវិនិច្ឆ័យដែលត្រូវពិចារណាសម្រាប់ការជ្រើសរើសមុខដំណាំនៅពេលអ្នកចាប់ផ្តើមការរៀបចំផែនការផលិតកម្ម៖**

| លរ | ឈ្មោះបន្លែ | ទិន្នផលជាមធ្យម (តោន/ហត) | រដូវដំណាំ | តម្លៃប៉ាន់ស្មាន (៛)/គក | តម្រូវការកម្លាំងពលកម្ម | សត្វល្អិត និងជំងឺ | តម្រូវការទឹក | ផលចំណេញ |
|---|---|---|---|---|---|---|---|---|
| | **បន្លែផ្លែ** | | | | | | | |
| 1 | ត្រសក់ | 25 | 4 | 1.200 | ** | ** | ** | ** |
| 2 | សណ្តែកគួរ | 22 | 4 | 2.000 | ** | * | * | * |
| 3 | ម្ទេសហាវ៉ៃ | 10 | 2 | 4.000 | * | **** | ** | *** |
| 4 | ប៉េងប៉ោះ | 30 | 2 | 2.000 | * | **** | ** | *** |
| 5 | ឪឡឹកលឿង | 35 | 4 | 1.500 | * | *** | * | **** |
| 6 | ត្រប់ | 33 | 2 | 1.500 | * | ** | * | ** |
| 7 | ម្រះ | 35-40 | 3 | 1.800 | ** | ** | * | *** |
| 8 | ល្ពៅ | 13 | 3-4 | 1.200 | * | ** | * | ** |
| 9 |ននោងមូល | 30 | 2 | 1.250 | * | ** | * | ** |
| 10 | ននោងជ្រុង | 30 | 2 | 1.200 | * | ** | * | ** |
| 11 | ពោត | 10 | 4 | 1.600 | * | * | *** | *** |
| 12 | ត្រឡាច | 25 | 3-4 | 1.300 | ** | * | * | ** |
| | **បន្លែស្លឹក** | | | | | | | |
| 13 | ត្រកួន | 25 | 8 | 2500 | *** | * | ***** | **** |
| 14 | ស្ពៃតឿ | 25 | 8 | 2500 | **** | **** | ***** | **** |
| 15 | ស្ពៃក្តោប ឬ ខាត់ណាដើម | 30 | 3 Or 6 | 3000 | ** | ***** | *** | ** |
| 16 | ស្ពៃខៀវ | 30 | 8 | 2500 | **** | *** | **** | *** |
| 17 | ស្ពៃចង្កឹះ | 30 | 8 | 3000 | **** | **** | **** | *** |
| | **បន្លែមើម** | | | | | | | |
| 18 | ដៃថាវ | 24 | 4 | 1.300 | **** | ***** | **** | *** |

**ចំណាំ៖**

*ការបង្ហាញកម្រិតវាយតម្លៃ៖
* = ទាប
** = មធ្យម
*** = ខ្ពស់
**** = ខ្ពស់ខ្លាំង
***** = ខ្ពស់បំផុត



**SNV កម្ពុជា**
#១២០ ផ្លូវ៥១(កែង២២៨) ជាន់ទី៥ ភូមិទី៤ សង្កាត់ចតុមុខ ខណ្ឌដូនពេញ
ក្រុងភ្នំពេញ កម្ពុជា

**ទូរស័ព្ទ៖** +៨៥៥ ១៧ ៦៤៤ ៨៨២
**អ៊ីម៉ែល៖** cambodia@snv.org
**គេហទំព័រ៖** www.snv.org/country/cambodia
**ហ្វេសប៊ុក៖** @SNVCambodia